# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*"ការងារស្អីធំជាងអង្គការទៀត? បើចង់ចៀសមិនធ្វើមិនដឹងចៀសទៅកន្លែងណា*
*នៅជាមួយត្រីក្នុងទឹកក៏នៅអត់បាន ហើរលើមេឃក៏អត់មាន អត់ចេះហើរលើមេឃ*
*ចេះតែធ្វើតាមគេប្រាប់ទៅ ដោយសារគេប្រាប់អីចឹង ធ្វើតាមគេតែទាំងអស់ ។"*

***-ដើមបណ្តឹងរដ្ឋប្បវេណី លោក ភ្លាន ហ៊ីត***

## *ជំពូកទី១ ៖* និដ្ឋភាពទូទៅ

ដំណើរការនីតិវិធីនៅក្នុងសប្តាហ៍នេះ ជាការចាប់ផ្តើមទទួលយកនូវភស្តុតាងសម្រាប់សំណុំរឿង ០០២ វគ្គទី១ ។ យោងតាមដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ។ សំណុំរឿង ០០២ វគ្គទី១ ត្រូវបានកំណត់ត្រឹមតែការទទួលយកទឡ្ហីករណ៍ទាំងឡាយណាដែលទាក់ទងនឹងបញ្ហាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ អំពីតួនាទីរបស់ជនជាប់ចោទមុនរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីការជម្លៀសដោយបង្ខំលើកទីមួយ និងលើកទីពីរ ដូចដែលមានការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអំពីឧក្រិដ្ឋកម្មនានាដែលទាក់ទងនឹងបញ្ហាដូចបានថែងខាងលើនេះ[1] លើកលែងតែអង្គជំនុំជម្រះសាលាដំបូងរកឃើញថាមាន "កាលៈទេសៈពិសេសៗ" ឬចាំបាច់ណាមួយ ដែលគួរតែអនុញ្ញាតឱ្យមានការចោទសួរលើទិដ្ឋភាពទាំងមូលនៃសំណុំរឿង០០២[2] ។

ដំណើរការនីតិវិធី បានចាប់ផ្តើមដោយមានក្រឡាបញ្ជីពីរនាក់អានកថាខណ្ឌមួយចំនួន ក្នុងដីកាដំណោះស្រាយដែលទាក់ទងនឹងប្រវត្តិសាស្រ្តបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសាវតារផ្ទាល់របស់ជនជាប់ចោទម្នាក់ៗ ។ បន្ទាប់មក អង្គជំនុំជម្រះបានស្តាប់ការផ្តល់សក្ខីកម្មពីលោក **នួន ជា** ពីភាគីដើមបណ្តឹងរដ្ឋប្បវេណីពីររូប និងសាក្សីសាមញ្ញមួយរូប ។

សវនាការដំបូងក្នុងសប្តាហ៍ទីមួយនេះ បានពើបប្រទះនូវការភាន់ច្រឡំដ៏ធ្ងន់ធ្ងរផ្នែកនីតិវិធីមួយចំនួនដែលបញ្ហាទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ដល់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងការគ្រប់គ្រងអង្គសវនាការប្រកបដោយប្រសិទ្ធភាព ។ បញ្ហាដែលបានកើតឡើងទាំងនោះរួមមាន៖

- សំណួរមួយចំនួនលើកឡើងដោយភាគីសហព្រះរាជអាជ្ញា និងភាគីក្រុមការពារក្តីស្តីពីថាតើត្រូវសួរដេញដោលរបៀបណាចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានចាត់ទុកថាជាការប្រព្រឹត្តដ៏ត្រឹមត្រូវគួរអនុវត្តតាម
- វិសាលភាពនៃសំណួរទាំងឡាយដែលត្រូវបានអនុញ្ញាតឲ្យសួរ (អាចសួរបាន) ផ្អែកលើខ្លឹមសារដែលបានកំណត់នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី
- តម្លៃជាភស្តុតាងជាក់លាក់នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពអាចអនុញ្ញាតបានចំពោះសំណួរនាំមុខ (leading questions) ក្នុងចំណោមសំណួរផ្សេងៗទៀត ។

ខណៈមានការជំទាស់មួយចំនួន បូករួមទាំងសំណួរផ្សេងៗដែលផុសចេញពីដើមចមជាក់ស្តែងក្នុងអំឡុងពេលដំណើរការនីតិវិធីក្នុងសប្តាហ៍នេះដែលបាននឹងកំពុងប្រព្រឹត្តទៅនោះ ការឆ្លើយតបរបស់អង្គជំនុំជម្រះចំពោះក្តីកង្វល់ទាំងឡាយរបស់ភាគី ជាទូទៅមិនមានលក្ខណៈច្បាស់លាស់ ហើយក៏គ្មានភាពស៊ីចង្វាក់គ្នាដែរ ។ មិនត្រឹមតែប៉ុណ្ណឹងទៀតសោត អង្គជំនុំជម្រះបានខកខានមិនបានផ្តល់នូវដំណោះស្រាយជាក់លាក់អ្វីមួយលើបញ្ហាទាំងអស់នោះឡើយ ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង មិនផ្លាស់ប្តូរវិធីសាស្ត្រក្នុងការគ្រប់គ្រងនូវសវនាការបែបនេះទេនោះ គេរំពឹងថា ដំណើរការជជែកវែកញែកដែលគ្មានដំណោះស្រាយចេញពីបទដ្ឋាននីតិវិធីដែលមិនច្បាស់លាស់ទាំងនេះ នឹងនាំឲ្យកាន់តែប្រើរយៈពេលវែង និងមានការភាន់ច្រឡំឥតប្រយោជន៍ជាក់ជាមិនខាន ។

## *ជំពូកទី២ ៖* ការសន្ទេបសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

នៅថ្ងៃទីមួយនៃសវនាការសប្តាហ៍នេះ លោក **នួន ជា** គឺជាបុគ្គលដំបូងគេដែលបានផ្តល់សក្ខីកម្មស្ទើរតែពេញមួយថ្ងៃ និងបានសុំអនុញ្ញាតទៅសម្រាកត្រឹមរសៀលម៉ោង ៣ និង២០នាទី ដោយសារគាត់អស់កម្លាំងពេក ។ នៅថ្ងៃទីពីរ លោក **នួន ជា** បានបន្តផ្តល់សក្ខីកម្មប្រមាណជាមួយភាគបួនតែប៉ុណ្ណោះ (វគ្គពេលព្រឹក) ប៉ុន្តែក្រោយមក គាត់បានជូនដំណឹងទៅអង្គជំនុំជម្រះថា គាត់ឡើយហត់ពេកទៅហើយ និងមិនអាចផ្តល់ចម្លើយឆ្លើយតបនឹងសំណួរបានល្អិតល្អន់នោះទេ ។ តាមការថ្លឹងថ្លែងនូវបញ្ហាសុខភាពជាក់ស្តែងរបស់លោក **នួន ជា** ក៏ដូចជាការបង្ហាញឲ្យឃើញនូវកិច្ចសហការណ៍ក្នុងការឆ្លើយតបនឹងសំណួរមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមតាមសំណូមពររបស់ជនជាប់ចោទរូបនេះ ។

ព្រោះតែលោក **នួន ជា** ត្រូវការការសម្រាកពីការផ្តល់សក្ខីកម្ម អង្គជំនុំជម្រះសាលាដំបូងបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណី លោក **ភ្លាន ហ្វៀត** មកផ្តល់សក្ខីកម្មនៅពេលរសៀលវិញ ។ នៅថ្ងៃពុធ សាក្សីសាមញ្ញម្នាក់គឺលោក **ឡុង នរិន្ទ** និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត គឺលោក **រ៉ូម៉ម យ៉ុន** ក៏បានផ្តល់សក្ខីកម្មផងដែរ ។ លោក **ឡុង នរិន្ទ** តាមដឹងមកថា គឺជាអតីតកម្មាភិបាលថ្នាក់កណ្តាលម្នាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធវីដេអូ ហើយសក្ខីកម្មរបស់គាត់បានបន្តរហូតដល់ពេញមួយថ្ងៃព្រហស្បតិ៍នេះ ។ សក្ខីកម្មរបស់លោក **ឡុង នរិន្ទ** បានផ្តោតលើការងាររបស់គាត់ក្នុងនាមជាបក្ខជនបដិវត្តន៍កុម្មុយនីស្តម្នាក់នៅ*ក្រុងប៉េកាំង* និង*ក្រុងហាណូយ* តាំងពីមុនឆ្នាំ១៩៧៥ មកម្ល៉េះ ។ គាត់ក៏បានឆ្លើយសំណួរទាក់ទងនឹងការជាប់ពាក់ព័ន្ធរបស់គាត់ចាប់ពីខែមេសា ១៩៧៥ ដល់ខែមករា១៩៧៩ ជាមួយក្រសួងការបរទេស ដែលកាលណោះត្រូវបានដឹកនាំដោយជនជាប់ចោទ **អៀង សារី** ។

ដោយឡែកដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូប បានផ្តល់សក្ខីកម្មស្រដៀងគ្នាអំពីបទពិសោធន៍ទាំងឡាយទាំងពួងក្នុងនាមជាសមាជិកនៃចលនាតស៊ូជាមួយខ្មែរក្រហមតាំងពីអំឡុងឆ្នាំ ១៩៧០ មក ។ ពួកគាត់ទាំងពីររូបបានផ្តល់សក្ខីកម្មជាភាសាខ្មែរ ទោះបីវាមិនមែនជាភាសាកំណើតរបស់ពួកគាត់ក៏ដោយ ។ ដោយសារមិនមានវត្តមានរបស់អ្នកបកប្រែអាជីពសម្រាប់ភាសាដើម *"កាចុក"* របស់ពួកគាត់ បុគ្គលិកមកពីអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញនៃ*អ.វ.ត.ក* បានអង្គុយអមដើម្បីជួយសួរសំណួរខ្លះៗឡើងវិញ និងបានជួយពន្យល់សំណួរទាំងនោះដល់ពួកគាត់ ។ ផលលំបាកនេះ បូករួមទាំងបញ្ហាមួយចំនួនទៀតរួមមាន៖ ភាពចាស់ជរា សុខភាពមិនរឹងមាំ ចន្លោះពេលវេលាដ៏វែងឆ្ងាយប្រមាណជា៤០ឆ្នាំនៃព្រឹត្តិការណ៍ដែលបានកើតឡើងត្រូវឲ្យពួកគាត់រម្លឹកនៅពេលនេះ ហើយប្រហែលជារួមបញ្ចូលទាំងការមិនស្ទាត់ជំនាញក្នុងការនិយាយ ឬអានភាសាខ្មែរផងនោះ បានធ្វើឲ្យកាន់តែមានការលំបាកទ្វេរឡើងក្នុងការសួរដេញដោលពីសំណាក់ភាគីផ្សេងៗ ។ ជាញឹកញាប់ ដែលចម្លើយរបស់ពួកគាត់មិនបានឆ្លើយតបនឹងសំណួរដែលបានសួរនោះទេ ។

## ក. សក្ខីកម្មរបស់លោក នួន ជា

ក្រោយពីប្រធានអង្គជំនុំជម្រះសាលាដំបូង លោកចៅក្រម **និល ណុន** បានរម្លឹកជាសង្ខេបអំពីសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងបទចោទប្រកាន់លើពួកគាត់រួចមក អង្គជំនុំជម្រះបានចាប់ផ្តើមដំណើរការនីតិវិធីលើអង្គសេចក្តី ដោយចោទសួរជនជាប់ចោទមួយរូបមុនគេ គឺលោក **នួន ជា** ។ ដំបូងទី គាត់ត្រូវបានសួរអំពីសាវតារផ្ទាល់ខ្លួន និងប្រវត្តិនៃចលនាតស៊ូក្នុងជួរបដិវត្តន៍ ។ បន្ទាប់មក លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បានសួរសំណួរជាក់លាក់មួយចំនួនអំពីសកម្មភាពរបស់លោក **នួន ជា** ពាក់ព័ន្ធជាមួយនឹងចលនាកុម្មុយនីស្ត ។ ស្ទើរតែទាំងអស់នៃសក្ខីកម្មរបស់លោក **នួន ជា** បានចោទប្រកាន់ប្រទេសវៀតណាមថាបានទទួលខុសត្រូវក្នុងការកាប់សម្លាប់រង្គាលក្នុងប្រទេសកម្ពុជា និងថារដ្ឋាភិបាលប្រទេសនេះមានចេតនាលេបត្របាក់យកទឹកដីប្រទេសកម្ពុជាតាំងពី

ដើមរហូតដល់បច្ចុប្បន្ននេះ ។

### *ក.១. ជីវប្រវត្តិផ្ទាល់ខ្លួន*

លោក **នួន ជា** បានបញ្ជាក់អះអាងថា ឈ្មោះកំណើតរបស់គាត់ គឺ **ឡៅ គឹមលន** ហើយថាឈ្មោះបដិវត្តន៍របស់គាត់ គឺ **នួន ជា** ។ គាត់កើតនៅថ្ងៃទី៧ កក្កដា ១៩២៦ ក្នុង*ភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង* ។ លោក **នួន ជា** ជាកូនទីបីក្នុងចំណោមកូនប្រាំបួននាក់ ។ ឪពុករបស់គាត់ជាកូនខ្មែរកាត់ចិន ប៉ុន្តែគាត់បញ្ជាក់ថាម្តាយរបស់គាត់ជាខ្មែរសុទ្ធដែលផ្ទុយពីព័ត៌មាននៅក្នុងដីកាដំណោះស្រាយ សរសេរថាម្តាយរបស់គាត់មានជាប់ខ្សែស្រឡាយចិនដែរនោះ[3] ។ គាត់បានរៀបការជាមួយអ្នកស្រី **លី គឹមសេង** ហើយពួកគាត់ទាំងពីរបានរស់នៅ*ស្រុកប៉ៃលិន* មុនពេលតុលាការចាប់ខ្លួនគាត់ ។ បន្ទាប់ពីរៀនចប់បឋមសិក្សាក្នុងប្រទេសកម្ពុជា លោក **នួន ជា** បានចូលរៀននៅអនុវិទ្យាល័យមួយក្នុង*ខេត្តបាត់ដំបង* ។ ពេលនោះ ក្នុងអំឡុងឆ្នាំ១៩៤១ *ខេត្តបាត់ដំបង*ត្រូវបានត្រួតត្រាដោយប្រទេសថៃ។ ក្រោយមក គាត់បានទៅសិក្សានៅ*សាកលវិទ្យាល័យធម្មសាត* (សាកលវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងសីលធម៌) ក្នុងប្រទេសថៃ និងបានធ្វើការក្រៅម៉ោងជាស្មៀននៅក្នុងក្រសួងហិរញ្ញវត្ថុប្រទេសថៃផងដែរ មុនពេលគាត់ទទួលបានការងារថ្មីនៅក្នុងក្រសួងការបរទេសប្រទេសថៃ ។ លោក **នួន ជា** បានវិលចូលប្រទេសកម្ពុជាវិញដើម្បីចូលរួមក្នុងចលនាតស៊ូ ក្រោយពេលបានអានរបាយការណ៍មួយចំនួនអំពីការបាញ់សម្លាប់ប្រជាជនកម្ពុជាពីពួកមន្ត្រីបារាំង ។

### *ក.២. ជំនឿនយោបាយរបស់លោក នួន ជា*

តាមសម្តីរបស់លោក **នួន ជា** ថា កត្តាជម្រុញចិត្តរបស់គាត់ឱ្យចូលរួមក្នុងការតស៊ូនោះ កើតចេញពីការបានឃើញដោយផ្ទាល់នឹងភ្នែកតាំងពីគាត់នៅក្មេងនូវការជិះជាន់ទៅលើប្រជាជនកម្ពុជា ធ្វើឡើងដោយរដ្ឋាភិបាលអាណានិគមនិយមបារាំង និងម្ចាស់ដីជាអ្នកមានទ្រព្យធនច្រើន ។ គាត់បានទៅរៀនក្នុងប្រទេសថៃ ពីព្រោះគាត់ចង់បានបទពិសោធន៍ជីវិតពីប្រទេសឯករាជ្យមួយ ប៉ុន្តែមិនយូរប៉ុន្មាន គាត់ឃើញថាភាពអយុត្តិធម៌កើតមាននៅគ្រប់ទីកន្លែង។ លោក **នួន ជា** បានផ្តល់សក្ខីកម្មថា សូម្បីតែនៅក្នុងប្រទេសថៃ ក៏ពួកអ្នកមានជិះជាន់លើជនទន់ខ្សោយដែរ ។ ព្រោះតែចង់សិក្សាស្វែងយល់ពីបញ្ហានេះ នាំឱ្យគាត់ចាប់ផ្តើមអានឯកសារកុម្មុយនីស្តជាច្រើន ហើយមិនយូរប៉ុន្មាន គាត់បានប្រាកដក្នុងចិត្តថាលទ្ធិកុម្មុយនីស្ត ជាគន្លឹះក្នុងការរំដោះប្រជាជនចេញពីលទ្ធិអាណានិគម និងការជិះជាន់ ។

លោក **នួន ជា** បានពន្យល់ថា ដំបូងគាត់មិនបានយល់ច្បាស់ទេថាតើអ្វីទៅជាលទ្ធិកុម្មុយនីស្ត ប៉ុន្តែគាត់បានចេះដឹងកាន់តែច្រើនបន្តិចម្តងៗ ដោយមានការជួយពន្យល់បង្ហាត់បង្ហាញពីសំណាក់សាស្ត្រាចារ្យមួយចំនួននៅក្នុងសាកលវិទ្យាល័យនោះ ។ គាត់បានចូលរួមក្នុង*អង្គការយុវជនប្រជាធិបតេយ្យក្នុងប្រទេសថៃ* និងក៏បានចូលរួមផង

ដែរជាមួយ *បក្សកុម្មុយនីស្តថៃ* កាលពីឆ្នាំ១៩៥០ ។ បន្ទាប់មក គាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងបានធ្វើការជាអ្នកឃោសនាដើម្បីប្រមូលផ្តុំប្រជាជនឲ្យប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌ក្នុងប្រទេសកម្ពុជា ។ លោក **នួន ជា** បានកត់សម្គាល់ថា នៅពេលនោះចលនាឥស្សរៈឯករាជ្យ (ចលនាប្រឆាំងបារាំង) បានធ្វើសកម្មភាពរួចទៅហើយ ប៉ុន្តែគាត់មិនចាប់អារម្មណ៍ទៅលើចលនាឥស្សរៈទេ ពីព្រោះចលនានេះបង្កើតឡើង និងត្រួតត្រាដោយ *វៀតណាម* ។

ទោះបីជាបានរៀបរាប់ពីការគ្មានជំនឿចិត្តលើ*ពួកវៀតណាម* ក៏ដោយ ក៏លោក **នួន ជា** បាននិយាយរម្លឹកថា គាត់ធ្លាប់បានទៅរៀននៅ*វៀតណាមខាងជើង* ។ ខណៈកំពុងរៀនសូត្រនៅទីនោះ គាត់បានឃើញរបាយការណ៍មួយដែលសរសេរថា ក្រោយកម្ពុជាទទួលបានឯករាជ្យពីបារាំង *ប្រទេសកម្ពុជា* និង*ប្រទេសឡាវ* នឹងក្លាយទៅជាផ្នែកមួយនៃសហព័ន្ធឥណ្ឌូចិននៅក្រោមការត្រួតត្រារបស់*វៀតណាម* ។ រឿងនេះ បានធ្វើឲ្យគាត់មានការខកចិត្តយ៉ាងខ្លាំង ពីព្រោះគោលបំណងរបស់គាត់គឺចង់បានឯករាជ្យទាំងស្រុងដល់ប្រទេសកម្ពុជា ។ គាត់បាននិយាយថា ក្រោយ*កិច្ចព្រមព្រៀងក្រុងហ្សឺណែវ* ឆ្នាំ១៩៥៤ គាត់បានឃើញដោយផ្ទាល់អំពីរបៀបដែល*វៀតណាម*បានចាប់ផ្តើមអនុវត្តនូវចេតនាអាក្រក់របស់ពួកគេតាមរយៈការបញ្ជ្រាបចូលពួកឥស្សរៈដោយសម្ងាត់ ដែលក្រុមនេះធ្លាប់ជាចលនាជាតិនិយមប្រឆាំងនឹងបារាំង ។ *វៀតណាម* បានចាត់ឲ្យជនជាតិខ្មែរធ្វើជាអ្នកដាំស្ល និងជាទាហានវាយរង ប៉ុន្តែ មេបញ្ជាការធំៗ គឺជា*ជនជាតិវៀតណាម* ។

តាមការរៀបរាប់របស់លោក **នួន ជា** បក្សកុម្មុយនីស្តខ្មែរ មិនមានប្រភពកំណើតចេញពីការតស៊ូរបស់ជនជាតិខ្មែរខ្លួនឯងនោះទេ ផ្ទុយទៅវិញគាត់ថាអ្វីៗគ្រប់បែបយ៉ាងទាំងអស់ស្ថិតនៅក្រោមការត្រួតត្រាពី*ក្រុងហាណូយនៃប្រទេសវៀតណាម* ។ គាត់ក៏បានបន្តថ្លែងថា ប្រជាជនកម្ពុជាមិនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលតុលាការបានចោទប្រកាន់ឡើយ ប៉ុន្តែគឺ*ពួកវៀតណាម* ទៅវិញទេ ជាអ្នកដែលកាប់សម្លាប់ប្រជាជនកម្ពុជា ។ លោក **នួន ជា** បាននិយាយសង្កត់ធ្ងន់ថា *“គាត់មិនចង់ឲ្យមនុស្សជំនាន់ក្រោយ យល់ខុសអំពីប្រវត្តិសាស្ត្រថាខ្មែរក្រហមជាឧក្រិដ្ឋជន ជាមនុស្សអាក្រក់នោះទេ”* ។ បន្ទាប់មក គាត់បានបន្តព្រមានជាថ្មីម្តងទៀត ថា*វៀតណាម*នៅតែក្រាញននៀលរហូតដល់សព្វថ្ងៃក្នុងការអនុវត្តផែនការឈ្លានពានរបស់គេ ហើយថាប្រសិនបើប្រជាជនកម្ពុជាមិនព្យាយាមការពារប្រទេសទេ កម្ពុជានឹងត្រូវ*វៀតណាម*លេបជាក់ជាមិនខានឡើយ ។

### *ក.៣. ការជាប់ពាក់ព័ន្ធដំបូងរបស់លោក នួន ជា ក្នុងបក្សកុម្មុយនីស្តកម្ពុជា*

ក្នុងការឆ្លើយតបនឹងសំណួរជាក់លាក់ពីចៅក្រម **ខាតវ៉ាយថ៍** លោក **នួន ជា** បានសារភាពថា ដំបូងគាត់បានចូលរួមក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន នៅពេលគាត់មកដល់ប្រទេសកម្ពុជាក្រោយពីបញ្ចប់ការសិក្សាក្នុងប្រទេស *ថៃ* ពីព្រោះមាន*ជនជាតិវៀតណាម*ម្នាក់បានផ្តល់យោបល់ឲ្យគាត់ថា គាត់ត្រូវតែចូលនៅក្នុងបក្សនេះទើបអាចធ្វើ

សកម្មភាពបដិវត្តន៍ក្នុងប្រទេសកម្ពុជាបាន ។ គាត់បាននិយាយបញ្ជាក់ឡើងវិញថា បក្សកុម្មុយនីស្តឥណ្ឌូចិន បានចែកចេញជាបីបក្ស ដោយក្នុងនោះបូករួមទាំងបក្សប្រជាជនខ្មែរបដិវត្តន៍ក្នុងប្រទេសកម្ពុជាផងដែរ ។ យោង តាមសម្ដីរបស់ លោក **នួន ជា** ក្នុងចំណោមបក្សទាំងបីនេះ គ្មានបក្សណាមួយដែលឯករាជ្យមិនស្ថិតក្រោមការគ្រប់ គ្រងរបស់*វៀតណាម*ឡើយ ។ ព្រោះតែមានការចាប់អារម្មណ៍ក្នុងការបង្កើតបក្សនយោបាយឯករាជ្យមួយនៅក្នុង ប្រទេសខ្លួននោះ លោក **នួន ជា** បានចូលរួមជាមួយលោកតា **ទូ សាមុត** និង **សាឡុត ស** (ដែលក្រោយមកប្រើ ឈ្មោះថា "**ប៉ុល ពត**") ដើម្បីបង្កើតបក្សមួយឈ្មោះ *"បក្សកម្មករខ្មែរ"* ដោយមិនមានការអនុម័តពី*វៀតណាម*ទេ។ ពេលនោះ លោកតា **ទូ សាមុត** បានក្លាយជាលេខាបក្ស ហើយលោក **នួន ជា** ផ្ទាល់ជាលេខារង ។ ក្រោយមក បក្សនេះបានដូរឈ្មោះទៅជា *"បក្សកុម្មុយនីស្តកម្ពុជា"* ដើម្បីចៀសវាងការយល់ច្រឡំជាមួយបក្សផ្សេងទៀតពាក់ ព័ន្ធនឹង*វៀតណាម* ។ ក្រោយពេលលោកតា **ទូ សាមុត** បាត់ខ្លួន លោក **ប៉ុល ពត** បានបន្តកាន់តំណែងជាលេខាបក្ស ហើយលោក **នួន ជា** នៅតែជាលេខារងដដែល ។

លោក **នួន ជា** បានគូសបញ្ជាក់ថា គាត់មិនដែលបានទទួលការបណ្ដុះបណ្ដាលផ្នែកយោធាក្នុង*ប្រទេស វៀតណាម* ដូចដែលតុលាការបានចោទនៅក្នុងដីកាដំណោះស្រាយឡើយ ។ គាត់ក៏បានបដិសេធថា គាត់មិនមាន ចំណែកអ្វីក្នុងគណៈកម្មការយោធាទេ ។ ប៉ុន្តែគាត់អះអាងថា គាត់ទទួលខុសត្រូវផ្នែកឃោសនាការ និងការអប់រំ គ្រប់កម្រិតក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ បន្ទាប់ពីបានស្នាក់នៅក្នុង*ប្រទេសវៀតណាម*កាលពីឆ្នាំ១៩៥១ ដល់ ១៩៥៣ លោក **នួន ជា** បានវិលត្រឡប់មកនៅក្រុងភ្នំពេញវិញ ។ ក្នុងអំឡុងពេលផ្ដល់សក្ខីកម្មនៅបន្ទប់សវនាការ លោក **នួន ជា** បានរៀបរាប់អំពីការលំបាកជាច្រើនដែលគាត់បានជួបប្រទះក្នុងការធ្វើសកម្មភាពបដិវត្តន៍ ក្រោយពី វិលត្រឡប់ចូលមាតុប្រទេសវិញ ។ គាត់ក៏បានពន្យល់បន្ថែមទៀតស្ដីអំពីមាគ៌ាយុទ្ធសាស្ត្រ និងកលយុទ្ធរបស់បក្ស កុម្មុយនីស្តដែលគាត់បានបង្កើតរួមគ្នាជាមួយលោក **ប៉ុល ពត** ។ យោងតាមជនជាប់ចោទ គោលនយោបាយស្នូល របស់បក្ស គឺត្រូវសង្គ្រោះអ្នកក្រ និងកសិករឲ្យរួចផុតពីការជិះជាន់ពីពួកវណ្ណៈសក្តិភូមិ ក៏ដូចជា ត្រូវលុបបំបាត់ ប្រព័ន្ធពាក់កណ្ដាលសក្តិភូមិ និងពាក់កណ្ដាលអាណានិគម ។ គាត់បានកត់សម្គាល់ថា *ប្រទេសចិន* បានគាំទ្រមាគ៌ា បក្សរបស់គាត់ ប៉ុន្តែក៏*វៀតណាម* បានប្រឆាំងដាច់អហង្ការ ព្រមទាំងបានព្យាយាមរារាំងផែនការបដិវត្តន៍របស់ ចលនាតស៊ូនេះឥតស្រាកស្រាន្ត ។

## ខ. សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន ហ្វីត

ដើមបណ្ដឹងរដ្ឋប្បវេណីដំបូង ដែលចូលខ្លួនក្នុងបន្ទប់សវនាការនាសប្ដាហ៍នេះ គឺលោក **ក្លាន ហ្វីត** មាន អាយុ៦៥ឆ្នាំ ជា*ជនជាតិភាគតិចកាចុក* មកពីខេត្តរតនគិរី[4] ។ គាត់និយាយភាសាខ្មែរ ជាមួយនឹងសំនៀងខ្មែរដើនៗ ដើមបណ្ដឹងរដ្ឋប្បវេណី បានតំណាលប្រាប់អំពីចំណងទាក់ទងនឹងប្រវត្តិរឿងរ៉ាវពីអតីតកាល ចាប់ផ្ដើមដោយការ ប្រៀបប្រដូចខ្លួនគាត់ជាបុរសសាមញ្ញម្នាក់ស្ថិតក្នុងភាពកោលាហលនាសម័យកាលនោះ ហើយត្រូវបង្ខំចិត្តខ្លួនឯង

ឲ្យចូលរួមក្នុងចលនាមួយដែលគាត់មិនទាំងបានយល់ផងថាអ្វីទៅជាបដិវត្តន៍នោះ ។ គាត់បានរម្លឹកថា គឺ*ជនជាតិឡាវ* ដែលបានអូសទាញគាត់ឲ្យចូលរួមក្នុងចលនានេះ ។ *ជនជាតិឡាវ*ទាំងនោះបាននិយាយកំហែងថា បើគាត់មិនចូលរួមទេ ពួកគេ *"នឹងមិនអាចរស់រានមានជីវិតបានទេ"* ហើយថា *"គេត្រូវការធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសចេញពីខ្មាំង និងពួកសក្តិភូមិ"* ។

ដោយក្រឡេកមើលទៅអតីតកាលវិញ លោក **ក្លាន ហ្វីត** បានប្រកាសថាខ្មែរក្រហមបានកេងប្រវ័ញ្ចលើជនជាតិដើមភាគតិច ដែលត្រូវបានគេបោះបង់ និងគ្មានការអប់រំ ។ ពីដំបូង លោក **ក្លាន ហ្វីត** បានធ្វើការជាអ្នកនាំសារ អ្នករត់សំបុត្រ និងជាបុគ្គលម្នាក់សម្រាប់គេធ្វើប្រាស្រ័យទាក់ទង ។ គាត់បានចូលរួមប្រជុំចំនួនពីរដង ក្រោមអធិបតីភាពរបស់លោក **អៀង សារី** ។ មុនឆ្នាំ១៩៧០ គាត់ និងអ្នកភូមិដទៃទៀត បានធ្វើផ្ទះការពារ (លេនដ្ឋានតែអាចស្នាក់នៅបាន) សម្រាប់លោក **ប៉ុល ពត** និង **អៀង សារី** ។ ផ្ទះលេនដ្ឋាននោះ នៅក្នុងជំរុំមួយ ឈ្មោះ *ក-៥* ស្ថិតនៅកន្លែងដ៏មានសុវត្ថិភាពនៅក្នុងព្រៃ ។ គ្រានោះ ពួកគាត់មិនដឹងទេថា បុរសទាំងនោះជាមេដឹកនាំបដិវត្តន៍ឡើយ ប៉ុន្តែនៅក្នុងសក្ខីកម្មដែលគាត់ផ្តល់ក្នុងពេលក្រោយមកទៀត លោក **ក្លាន ហ្វីត** បានបញ្ជាក់ថា **ប៉ុល ពត** និង **អៀង សារី** ជាមេដឹកនាំសំខាន់របស់បដិវត្តន៍ ហើយគាត់ដឹងថាឈ្មោះបដិវត្តន៍របស់លោក **អៀង សារី** នៅពេលនោះគឺ "**វ៉ាន់**" ។

លោក **ក្លាន ហ្វីត** បានរៀបរាប់ថា គាត់ត្រូវបានតែងតាំងជាមេភូមិ និងទទួលខុសត្រូវក្នុងការអនុវត្តការកំណត់បរិមាណផលិតផលកសិកម្មថ្នាក់ភូមិ ដែលបានដាក់ចេញដោយខ្មែរក្រហម ។ ក្រោយមកមិនយូរប៉ុន្មានគាត់ត្រូវតែងតាំងឲ្យក្លាយជា*មេឃុំតាឡៅ ស្រុកបរកែវ* និង ក្រោយមកទៀតនៅ*ស្រុកអណ្តូងមាស* ។ បន្ទាប់ពី *"រំដោះ"* បានក្រុងភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានខ្មែរក្រហមអញ្ជើញឲ្យចូលរួមវគ្គបណ្តុះបណ្តាលនយោបាយក្រោមអធិបតីភាពរបស់លោក **នួន ជា** បានចំនួនពីរដងនៅក្នុងទីក្រុងភ្នំពេញ ។ ក្នុងឆ្នាំ១៩៧៦ គាត់ត្រូវបានតែងតាំងឲ្យក្លាយជាលេខារងក្នុងស្រុកកំណើតរបស់គាត់។ លោក **ក្លាន ហ្វីត** បានបង្ហាញឲ្យឃើញថាគាត់ទទួលរងការលំបាកជាច្រើនក្នុងពេលកាន់តំណែងមួយនេះ ដោយសារតែគេបញ្ជាឲ្យធ្វើការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន និងប្រមូលផ្តុំប្រជាជនទៅកន្លែងផ្សេងទៀតដើម្បីទៅធ្វើស្រែចម្ការ ហើយគាត់ត្រូវរកមើលផ្ទៃដីសម្រាប់ភ្ជួររាស់ដាំដុះផងដែរ ។ គាត់បាននិយាយទាំងសោកសៅថា *"ខ្ញុំត្រូវគេបំភ័យ គេគំរាមកំហែង ប៉ុន្តែខ្ញុំត្រូវតែស្តាប់ និងធ្វើតាមបញ្ជា គឺមិនត្រូវទុកដីឲ្យនៅទំនេរចោលឡើយ"* ។ ដោយសារការភ័យខ្លាចនេះ ប្រជាជនក៏ត្រូវស្តាប់តាមបញ្ជាខ្មែរក្រហម សូម្បីតែការមិនឲ្យប្រតិបត្តិសាសនាដើមរបស់ខ្លួន ។

នៅពេលលោក **ក្លាន ហ្វីត** ផ្តល់សក្ខីកម្មចប់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានសុំឲ្យគាត់ថ្លែងពីការខូចខាត ឬសេចក្តីរងទុក្ខវេទនាដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានទទួលរងនៅក្នុងរបបខ្មែរក្រហម ជាពិសេសទាក់ទងនឹងបណ្តឹងទាមទារសំណងរបស់គាត់ ។ លោក **ក្លាន ហ្វីត** ហាក់ដូចជាយល់ខុសអំពីគោលបំណងនៃការលើកឡើងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ តែគាត់បានផ្តល់នូវការរ៉ាយរ៉ាប់ជាទូទៅថា

គាត់បានឆ្លងកាត់ការលំបាកជាច្រើន ហើយមនុស្សមួយចំនួនដែលគាត់ស្គាល់ត្រូវគេសម្លាប់ ។ នៅថ្ងៃបន្ទាប់ លោក **ភ្លាន ហ្វីត** បានធ្លាក់ខ្លួនឈឺ និងមិនអាចបន្តផ្តល់សក្ខីកម្មបាន ។ អង្គជំនុំជម្រះបានជូនដំណឹងថា គាត់នឹងបន្តផ្តល់សក្ខីកម្មក្នុងខែមករា ២០១២ ។

### គ. សក្ខីកម្មរបស់លោក រ៉ូម៉ម យ៉ុន

លោក **រ៉ូម៉ម យ៉ុន** ដែលជាដើមបណ្តឹងរដ្ឋប្បវេណីទីពីរ បានចូលខ្លួនផ្តល់សក្ខីកម្មដោយបានរៀបរាប់ស្រដៀងគ្នាផងដែរអំពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម ។ លោក **រ៉ូម៉ម យ៉ុន** ជា*ជនជាតិដើមកាចុក*មានអាយុ ៧០ឆ្នាំ មកពី*ស្រុកអណ្តូងមាស ខេត្តរតនគិរី* ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏ជាអតីតកម្មាភិបាលដែលមានបទពិសោធន៍ផ្ទាល់ក្នុងរចនាសម្ព័ន្ធបញ្ជាការ និងប្រតិបត្តិការរបស់បក្សដូចលោក **ភ្លាន ហ្វីត** ដែរ ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក **គីម ម៉េងលី** បានផ្តល់យោបល់ដល់ភាគីដទៃទៀតឲ្យសួរសំណួរខ្លីៗ និងសាមញ្ញងាយយល់ ពីព្រោះសាក្សីមិនចេះអក្សរ មានសុខភាពទ្រុឌទ្រោម និងមានបញ្ហាទាក់ទងនឹងការចងចាំរបស់គាត់ ។ ការស្នើទាំងនេះបានលេចឡើងជាក់ស្តែងនៅពេល លោក **រ៉ូម៉ម យ៉ុន** ចាប់ផ្តើមផ្តល់សក្ខីកម្ម ។ ជាទូទៅ គាត់មិនអាចចាំកាលបរិច្ឆេទ ឬពេលវេលាជាក់លាក់ទាក់ទងនឹងព្រឹត្តិការណ៍ដែលគាត់បានរៀបរាប់ក្នុងការផ្តល់សក្ខីកម្មនោះទេ ។ ដូចគ្នានេះដែរ គាត់បានផ្តល់នូវចម្លើយដែលមិនឆ្លើយតបនឹងសំណួរដែលគេបានសួរនោះឡើយ ។

លោក **រ៉ូម៉ម យ៉ុន** បាននិយាយថាគាត់ចាំមិនបានទេ ថាខ្មែរក្រហមបានចូលដល់តំបន់គាត់នៅពេលណា និងបាននិយាយថា គាត់ត្រូវគេបង្ខំឲ្យចូលក្នុងជួរបដិវត្តន៍ ។ អ្នកទទួលបន្ទុកចុះឈ្មោះគាត់ចូលបញ្ជីបក្សបានប្រាប់គាត់ថា ការចូលជាសមាជិកបក្សទាមទារឲ្យគាត់មានឆន្ទៈ *"បម្រើជាតិ ត្រូវរំដោះជាតិ ត្រូវកសាងជាតិ និងត្រូវរួមអភិវឌ្ឍន៍ជនបទ និងតស៊ូដើម្បីដល់កូនចៅជំនាន់ក្រោយ"* ។ លោក **រ៉ូម៉ម យ៉ុន** ផ្តល់សក្ខីកម្មថា គាត់មិនដឹងថាគោលបំណងទាំងនេះនឹងត្រូវសម្រេចបានដោយរបៀបណានោះទេ តែទោះជាយ៉ាងណាក៏ដោយ គាត់បានចូលរួមរួចទៅហើយ ។

ពីដំបូង គេឲ្យគាត់ធ្វើជាអ្នកនាំសារសម្រាប់កម្មាភិបាលជាន់ខ្ពស់ ។ គាត់នៅចាំបានថា គាត់បាននាំសារជាច្រើនទៅឲ្យមនុស្សម្នាក់ឈ្មោះ "**វ៉ាន់**"[5] ប៉ុន្តែមិនបានបញ្ជាក់ច្បាស់ថា "**វ៉ាន់**" នោះជាលោក **អៀង សារី** ឬមិនមែននោះទេ ។ ក្រោយមក គាត់ត្រូវគេតែងតាំងឲ្យគ្រប់គ្រងការងារថ្នាក់ភូមិ និងការងារឃុំ ហើយបន្ទាប់ពីនេះមក គាត់បានក្លាយទៅជា*មេស្រុកអណ្តូងមាស* ។ គាត់បាននិយាយដែរថា ឈ្មោះ "**វ៉ាន់**" បានចូលរួមក្នុងកិច្ចប្រជុំមួយចំនួនក្នុងអំឡុងពេលបដិវត្តន៍ ។ ក្នុងពេលប្រជុំទាំងនោះ កម្មាភិបាលបានពិភាក្សាអំពីការធ្វើស្រែចម្ការ ការមានកិរិយាមាយាទសមរម្យ ការចេះសាមគ្គីគ្នា ការដោះស្រាយបញ្ហា និងផែនការសម្រាប់សកម្មភាពបដិវត្តន៍ ។ លោក **រ៉ូម៉ម យ៉ុន** បានពន្យល់ថា អ្នកដែលងាកចេញពីផែនការត្រូវបាន *"កម្ចាត់ ឬបណ្តេញចេញ"* ។ អ្នកជំទាស់

តវ៉ាទាំងនោះ ត្រូវគេចោទថាជាខ្មាំង ត្រូវគេចាប់ដាក់គុក ឬនាំយកទៅក្នុងព្រៃ ។ នៅពេលត្រូវបានចោទសួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពន្យល់អំពីរបៀបដែលអង្គការកំណត់ថាជា *"ខ្មាំង"* ដោយរបៀបណានោះ គាត់បានអះអាងថា *"ប្រសិនបើភូមិស្អាត នោះគឺគ្មានខ្មាំងទេ តែប្រសិនបើមិនស្អាត គឺមានខ្មាំងហើយ"* ។ គាត់សារភាពថាគាត់មិនសូវយល់ច្បាស់អំពីស្ថានភាពនៅពេលនោះទេ ។

នៅពេលព្រះរាជអាជ្ញាជាតិ **ច័ន្ទ តារាស្មី** បានសួរអំពីការជម្លៀសចេញនៅថ្ងៃ១៧ មេសា ១៩៧៥ នោះលោក **រ៉ូម៉ម យ៉ឺន** និយាយថា ប្រជាជនគ្រាន់តែបានឮព័ត៌មាននេះតពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ ហើយគាត់ផ្ទាល់មិនបានឃើញមានការផ្លាស់ប្តូរទីកន្លែងរស់នៅកើតឡើងក្នុងតំបន់របស់គាត់នោះទេ ។ ចម្លើយនេះបានបញ្ចប់នូវការសួរដេញដោលពីសំណាក់ភាគីសហព្រះរាជអាជ្ញាទៅលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ អង្គជំនុំជម្រះបានពន្យារពេលសម្រាប់ភាគីការពារក្តីដើម្បីធ្វើការសួរដេញដោលលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ រហូតដល់ខែមករា ឆ្នាំ២០១២ ពីព្រោះតុលាការចង់ផ្តល់អាទិភាពស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបដែលកំពុងមានជម្ងឺគឺលោក **ឡុង នរិន្ទ** ដែលអាចផ្តល់សក្ខីកម្មបានតែរយៈពេលយ៉ាងខ្លីបំផុតតាមរយៈវីដេអូលីង ។

## ឃ. សក្ខីកម្មរបស់លោក ឡុង នរិន្ទ

អង្គជំនុំជម្រះសាលាដំបូង បានស្តាប់នូវទឡ្ហីករណ៍អះអាងពីសាក្សីសាមញ្ញម្នាក់ក្នុងសប្តាហ៍នេះ គឺ លោក **ឡុង នរិន្ទ** ។ ដូចអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងឮដែរ សាក្សី **ឡុង នរិន្ទ** ធ្លាប់មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងជនជាប់ចោទមួយចំនួននៃរបបកម្ពុជាប្រជាធិបតេយ្យ និងអាចចែករំលែកចំណេះដឹងផ្ទាល់របស់គាត់អំពីប្រតិបត្តិការផ្ទៃក្នុងបក្សស្តីពីការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ព្រមទាំងរចនាសម្ព័ន្ធបញ្ជាការរបស់ខ្មែរក្រហមផងដែរ ។ បើទោះជាគាត់បានដឹងឮ និងមានទំនាក់ទំនងនឹងព្រឹត្តិការណ៍ជាក់លាក់មួយចំនួនក៏ដោយ ក៏គាត់បានស្នើក្នុងសក្ខីកម្មរបស់គាត់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ជាបុគ្គលសម្រាប់ទំនាក់ទំនងកណ្តាលទទួលបន្ទុកការងារថ្នាក់កណ្តាល ឬអាចនិយាយម្យ៉ាងទៀតថា ការទទួលខុសត្រូវរបស់គាត់ គឺគ្រាន់ច្រើនជាងលោក **ភួន ហ្វៀត** និងលោក **រ៉ូម៉ម យ៉ឺន** តែប៉ុណ្ណោះ ។ ដោយសារតែសុខភាពទ្រុឌទ្រោម លោក **ឡុង នរិន្ទ** ត្រូវបានតុលាការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មតាមរយៈការភ្ជាប់ប្រព័ន្ធវីដេអូពីផ្ទះរបស់គាត់ក្នុង*ខេត្តបន្ទាយមានជ័យ*។ នៅតាមកញ្ចក់វីដេអូ យើងអាចឃើញសាក្សីរូបនេះកំពុងអង្គុយក្នុងកន្លែងទទួលភ្ញៀវធម្មតាតាមរបៀបផ្ទះអ្នកស្រុក (មិនមានបន្ទប់ឃាំង ព្រោះបានឮសម្លេងរំខានពីខាងក្រៅមកច្រើន) ក្នុងផ្ទះរបស់គាត់ដោយមានបុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញនៅជាមួយគាត់ផងដែរ ។ ពួកគេ (បុគ្គលិក) ទាំងនោះ បានជួយសួរសំណួរឡើងវិញម្តងម្កាលនៅពេលមានការរអាក់រអួលពីប្រព័ន្ធវីដេអូលីង ស្តាប់សំណួរមិនបាន និងពេលខ្លះជួយពន្យល់សាក្សីឲ្យយល់បានច្បាស់នូវសំណួរដែលបានសួរទៅកាន់គាត់ ។ លោក **ឡុង នរិន្ទ** បានឃើញភាគីចោទសួរមកលើរូបគាត់ផ្លាស់គ្នាពីភាគីមួយទៅភាគីមួយទៀត តាមរយៈទស្សនីយភាពពីកញ្ចក់កុំព្យូទ័រ ។

### *ឃ.១. ជីវប្រវត្តិរបស់លោក ឡុង នរិន្ទ និងដំណើរជីវិតដំបូងក្នុងបក្សកុម្មុយនីស្តកម្ពុជា*

លោក **ឡុង នរិន្ទ** កើតក្នុងឆ្នាំ១៩៣៨ ក្នុង*ភូមិដូង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ* ហើយសព្វថ្ងៃគាត់ ក៏កំពុងតែរស់នៅទីនោះដដែល ។ គាត់និយាយប្រាប់តុលាការថាគាត់ជាកសិករមួយរូប ។ ពីឆ្នាំ១៩៦០ ដល់១៩៧១ គាត់សិក្សាផ្នែកកាយសម្ព័ន្ធវិទ្យានៅ*ទីក្រុងប្រាគ* ក្នុង*ប្រទេសឆេកូស្លូវ៉ាគី* ។ ដោយការយកចិត្តទុកដាក់ទៅនឹងការអំពាវនាវរបស់ **សម្តេច សីហនុ** ឲ្យកូនចៅព្រះអង្គចូលរួមប្រយុទ្ធតស៊ូដើម្បីផលប្រយោជន៍ប្រទេសជាតិ លោក **ឡុង នរិន្ទ** ក៏បានទៅ*ក្រុងប៉េកាំង* ដើម្បីចូលរួមចលនាតស៊ូ នៅទីនោះហើយគាត់បានជួបលោក **អៀង សារី** ។ បន្ទាប់ពីដំណើរមួយនេះ គាត់បានចេញទៅ*ក្រុងហាណូយ* និងបានធ្វើការក្នុងស្ថានីយ៍វិទ្យុនៃ*រណសិរ្សរួបរួមជាតិកម្ពុជា (FUNK)* ដែលដឹកនាំដោយអ្នកស្រី **អៀង ធីរិទ្ធ** ។ ក្រោយមកគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញតាមច្រកនៃ*ទីក្រុងហូជីមិញ* និងបានធ្វើការនៅ*ខេត្តស្ទឹងត្រែង*ជាកសិករនៅ*ការិយាល័យ ប-២០* និង *ប-១៥* ។ តពីនេះមក លោក **នួន ជា** និងលោក **ខៀវ សំផន** បានបញ្ជូនគាត់ឲ្យទៅប្រចាំការនៅ*ខេត្តព្រះវិហារ* ដើម្បីសិក្សាស្វែងយល់ពីស្ថានភាពប្រជាជន និងតម្រូវការរបស់ពួកគេ ។

ក្រោយពេល "រំដោះ" ទីក្រុងភ្នំពេញបាននៅថ្ងៃ១៧ មេសា ១៩៧៥ លោក **ឡុង នរិន្ទ** បានទទួលបញ្ជាឲ្យទៅភ្នំពេញ ។ សាក្សីបានឲ្យដឹងថា គាត់បានមកដល់ភ្នំពេញក្នុងអំឡុងពេលមានការជម្លៀស ។ ទោះជាយ៉ាងនេះក្តី លោក **ឡុង នរិន្ទ** បានអះអាងថា គាត់មិនដឹងថាគេកំពុងជម្លៀសប្រជាជននោះទេ ។ គាត់និយាយថា គាត់ឃើញតែប្រជាជនកំពុងដើរចេញពីរាជធានី ប៉ុន្តែគាត់មិនដឹងថាពួកគេធ្វើដំណើរទៅណាមកណាឡើយ ។ នៅភ្នំពេញ លោក **ឡុង នរិន្ទ** ត្រូវគេចាត់តាំងឲ្យទៅធ្វើការនៅ*ការិយាល័យ ប-១* ដែលជាក្រសួងការបរទេស ។

### *ឃ.២. ខ្សែរជីវិតនៅក្រសួងការបរទេស*

លោក **ឡុង នរិន្ទ** បានផ្តល់សក្ខីកម្មថា ចាប់ពីខែមេសា ១៩៧៥ ដល់ខែមករា ១៩៧៩ គាត់បានធ្វើការនៅក្រសួងការបរទេស ដឹកនាំដោយលោក **អៀង សារី** ។ នៅក្នុងក្រសួងនោះ ការងាររបស់គាត់រួមមានដូចជា៖ វាយឯកសារ រៀបចំលិខិតឆ្លងដែន និងធ្វើបញ្ជីការជនបរទេសដែលបានមកដល់ប្រទេសកម្ពុជា ។ សក្ខីកម្មរបស់លោក **ឡុង នរិន្ទ** ក៏មានរៀបរាប់អំពីពិសោធផ្ទាល់ខ្លួនស្តីពីភាពឆ្កួតលីលារបស់ខ្មែរក្រហម ដែលជឿលើការបង្កប់ខ្លួនរបស់ភ្នាក់ងារ *ស៊ី.អាយ.អេ* និង *កា.ហ្សេ.បេ* ។ យោងតាម លោក **ឡុង នរិន្ទ** ក្នុងអំឡុងឆ្នាំ១៩៧៦ ឬ១៩៧៧ អ្នកគ្រប់គ្រងផ្ទាល់ពីលើគាត់ បានណែនាំឲ្យគាត់រៀបចំជីវប្រវត្តិមួយ និងបានសួរគាត់ថាតើបានដឹងខ្លួនទេ ថាមានគេចោទប្រកាន់គាត់ថាជាសមាជិក *ស៊ី.អាយ.អេ* ។ លោក **ឡុង នរិន្ទ** និយាយថាគាត់មិនបានដឹងអំពីការសង្ស័យលើរូបលោកយ៉ាងដូច្នេះទេ ហើយថាសូម្បីតែលោក **អៀង សារី** ក៏ធ្លាប់បានសួរគាត់ដែរពីបញ្ហាដូចគ្នានេះ កាលនៅ*ទីក្រុងហាណូយ* ។ សាក្សីរូបនេះក៏បានរៀបរាប់ថាលោក **អៀង សារី** បានសួរគាត់ថាតើគាត់ស្គាល់បុគ្គលម្នាក់ឈ្មោះ

**ថាច់ ជា** ដែរឬទេ? (ជាមិត្តរួមសាលាកាលនៅសាលាគរុកោសល្យ និងជាមិត្តរួមក្រុមបាល់ទាត់ជាមួយគ្នានោះ) ។ លោក **ឡុង នរិន្ទ** គិតស្មានថា លោក **អៀង សារី** សួរគាត់អំពី **ថាច់ ជា** ពីព្រោះលោក **អៀង សារី** ជឿថាគាត់មានភាពជិតស្និទ្ធជាមួយនឹងអតីតមិត្តរួមសាលានោះ ។ សាក្សីរូបនេះបានសារភាពបន្ថែមទៀតថា គាត់ដឹងថា **ថាច់ ជា** នៅក្នុងក្រុម *ស៊ី.អាយ.អេ* ពីព្រោះគាត់មានទំនាក់ទំនងជាមួយស្ថានទូតជាច្រើន ។ គាត់ក៏បានពន្យល់ដែរថា មានស្ថានទូតមួយចំនួន មាននិន្នាការទាក់ទងជាមួយនឹងភ្នាក់ងារ *ស៊ី.អាយ.អេ* ប៉ុន្តែគាត់ផ្ទាល់បានបញ្ជាក់ថា គាត់ទាក់ទងជាមួយស្ថានទូតនៃប្រទេសសង្គមនិយមតែមួយចំនួនតូចប៉ុណ្ណោះ ។

នៅពេលចាប់ផ្តើមសវនាការថ្ងៃព្រហស្បតិ៍ ភាគីសហព្រះរាជអាជ្ញាបានស្នើឲ្យលោក **ឡុង នរិន្ទ** បញ្ជាក់ផ្ទៀងផ្ទាត់ឡើងវិញ ថាតើឯកសារដែលគេបង្ហាញគាត់នៅលើផ្ទាំងអេក្រង់កុំព្យូទ័រនោះ គឺជាជីវប្រវត្តិរបស់គាត់ ឬមិនមែន ។ សាក្សីបានពិនិត្យមើលឯកសារ ហើយបញ្ជាក់ថា អក្សរសរសេរដោយដៃនោះគឺជាអក្សររបស់គាត់ ។ គាត់បន្តពោលអះអាងថា ជីវប្រវត្តិរបស់គាត់នោះ គឺជាសាច់រឿងជីវិតពិត ។ សំខាន់ជាងនេះទៅទៀត មានផ្នែកមួយចំនួននៅក្នុងជីវប្រវត្តិរបស់លោក **ឡុង នរិន្ទ** បានរ៉ាយរ៉ាប់ពីបុគ្គលមួយចំនួន រួមមាន **ថាច់ ជា** និង **ទេព សំអាន** ដែលជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំ*ប្រទេសអាល់ហ្សេរី* ។ ការលើកឡើងដល់ឈ្មោះទាំងនេះ បាននាំឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ លោក **ដេលី សាក់** ចោទសួរថា នៅពេលដែលសាក្សីសរសេរជីវប្រវត្តិនោះ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ខ្លួន និងសម្លាប់ **ទេព សំអាន** រួចហើយ ។ លោក **ដេលី សាក់** បានសួរសាក្សី **ឡុង នរិន្ទ** បន្ថែមទៀតថា តើគាត់ដឹងទេថាប្រពន្ធ និងកូនៗរបស់ **ថាច់ ជា** ត្រូវគេចាប់ខ្លួន និងសម្លាប់ចោលនៅ*មន្ទីរ ស-២១* បន្ទាប់ពីការជម្លៀសចេញពីទីក្រុងភ្នំពេញដែរឬទេ ។ បន្ទាប់មក សហព្រះរាជអាជ្ញាក៏បានដេញដោលថា តើសាក្សីបានដឹងដែរទេ ថាឈ្មោះបុគ្គលមួយចំនួនដែលសាក្សីផ្ទាល់បានលើកឡើងនៅក្នុងជីវប្រវត្តិរបស់ខ្លួននោះ ត្រូវបានគេបញ្ជូនទៅកាន់*មន្ទីរ ស-២១* ។ លោក **ឡុង នរិន្ទ** បានអះអាងថា គាត់មិនបានដឹងថាមានរឿងចាប់ខ្លួន និងការកម្ទេចទាំងកើតឡើងនោះទេ ។

ភាគីសហព្រះរាជអាជ្ញា បានសួរថាតើលោកសាក្សីផ្ទាល់មានការភ័យខ្លាចឬទេ នៅពេលលោក **អៀង សារី** សួរថាតើគាត់មានជាប់ពាក់ព័ន្ធនឹង *ស៊ី.អាយ.អេ* មែនឬអត់ ហើយតើសាក្សីមានការភ័យខ្លាចទេ នៅពេលដែលគេតម្រូវឲ្យរៀបចំសរសេរជីវប្រវត្តិផ្ទាល់ខ្លួនរបស់គាត់យ៉ាងដូច្នេះ ។ លោក **ឡុង នរិន្ទ** ឆ្លើយថា “ខ្ញុំគិតថាគង់តែដល់វេនខ្ញុំនៅថ្ងៃណាមួយមិនខានទេ” ។ ចំណុចគួរឲ្យចាប់អារម្មណ៍មួយ គឺលោក **ឡុង នរិន្ទ** បានសារភាពថា គាត់មិនបានទទួលការទិតៀនរិះគន់ ឬទទួលការដាក់វិន័យណាមួយទេ បន្ទាប់ពីគាត់បានផ្ញើជីវប្រវត្តិរបស់គាត់ដល់ថ្នាក់លើហើយ ។ គាត់ហាក់ដូចជាបានរួចខ្លួនពីការកម្ទេចក្នុងចំណោមអ្នកបានទទួលការសិក្សាអប់រំពីបរទេសដែលធ្វើការនៅក្នុងក្រសួងនេះ ទោះបីជាឈ្មោះគាត់ត្រូវគេលើកឡើងនៅក្នុងចម្លើយសារភាពចំនួនបី នៅ*មន្ទីរ ស-២១* ក៏ដោយ ។ លោក **ឡុង នរិន្ទ** បានទទួលស្គាល់ថា មេដឹកនាំគាត់មិនដែលបានបញ្ជាឲ្យចាប់ខ្លួនគាត់ ឬយកគាត់ទៅរៀនសូត្រ (កសាង) នោះទេ ។

### *ឃ.៣. ភាពគួរជឿជាក់បាន និងភាពស្ទាក់ស្ទើររបស់សាក្សីក្នុងការផ្ដល់សក្ខីកម្ម*

ការផ្ដល់សក្ខីកម្មរបស់លោក **ឡុង នរិន្ទ** ជាទូទៅមានស៊ីចង្វាក់គ្នារវាងការឆ្លើយរបស់គាត់តបនឹងសំណួរដែលបានចោទសួរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពេលខ្លះនៃចម្លើយរបស់គាត់តបនឹងសេចក្ដីថ្លែងការណ៍ដែលបានធ្វើជាមួយចៅក្រមស៊ើបអង្កេតហាក់មានភាពប្រទាញប្រទង់គ្នា ហើយគាត់ក៏មិនបានចងចាំនូវព័ត៌មានលម្អិតមួយចំនួនឱ្យបានច្បាស់លាស់ដែរ ។ ចំណុចនេះ ត្រូវបានលាតត្រដាងនៅពេលសហមេធាវីដើមតំណាងបណ្ដឹងរដ្ឋប្បវេណី បានចោទសួរនូវសំណួរមួយចំនួនទៅកាន់រូបគាត់ ដែលសំណួរទាំងនោះមានខ្លឹមសារស្រដៀងនឹងសំណួរដែលភាគីសហព្រះរាជអាជ្ញាបានសួរហើយ ប៉ុន្តែសាក្សីបានឆ្លើយនូវចម្លើយផ្សេងគ្នាទៅវិញ ។ ជាក់ស្ដែង ពីមុនគាត់និយាយថា គាត់បានរស់នៅក្នុង*ក្រុងប៉ៃកាំង*ចំនួនកន្លះឆ្នាំ ប៉ុន្តែក្រោយមក គាត់បាននិយាយថា គាត់បាននៅ*ប៉ៃកាំង* រយៈពេលមួយឆ្នាំកន្លះ ។ ក្នុងករណីខ្លះ គាត់ហាក់ដូចជាចងចាំបានល្អជាងនៅពេលគាត់ត្រូវបានគេសួរជាលើកទីពីរ ជាពិសេសកាលៈទេសៈទាំងឡាយដែលទាក់ទងនឹងជីវប្រវត្តិរបស់គាត់ ដូចជាចំណុចដែលគាត់បញ្ជាក់ថា៖ លោក **អៀង សារី** ជាអ្នកដែលបានបញ្ជាឱ្យអ្នកគ្រប់គ្រងផ្ទាល់ពីលើគាត់ប្រាប់បន្តឱ្យគាត់សរសេរប្រវត្តិរូប ហើយត្រង់នេះជាចំណុចដែលមានការទាក់ទងនឹងជនជាប់ចោទ **អៀង សារី** ហើយដែលចំណុចនេះ គាត់មិនបាននិយាយទេកាលពីមួយម៉ោងមុន នៅក្នុងសក្ខីកម្មរបស់គាត់នោះ ។

លើសពីនេះទៀត លោក **ឡុង នរិន្ទ** ហាក់ដូចជាចង់គេចមិនឆ្លើយនៅពេលសួរអំពីការកម្ទេចនៅក្នុងក្រសួងការបរទេស និងការចូលរួមរបស់ជនជាប់ចោទ **អៀង សារី** ក្នុងការកម្ទេចទាំងនេះ ។ នៅពេលគេសួរថា តើមានរឿងអ្វីកើតឡើងចំពោះអ្នកដែលត្រូវគេចាត់ទុកថា *"សមាសភាពមិនល្អ មិនមានភាពស្អាតស្អំ"* ឬ ត្រូវគេរកឃើញថាជាជនក្បត់ជាតិ? សាក្សីបានឆ្លើយថា មិនមានរឿងអ្វីកើតឡើងទៅលើអ្នកទាំងនោះឡើយ ។ នៅពេលគេសួរបន្ថែមអំពីការចាប់ខ្លួនអតីតអ្នកការទូត និងបុគ្គលិករបស់ក្រសួងនេះ សាក្សីបាននិយាយដដែលៗថា គាត់មិនបានដឹងច្បាស់ពីរឿងនោះទេ ហើយគាត់មិនបានចងចាំ ហើយក៏មិនបានដឹងឮដែរ ។ ចំណុចនេះ បានធ្វើឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ លោក **ដេលីសាក់** សួរផ្ចាញ់ទៅកាន់សាក្សីរូបនេះ ដោយបានសួរថា *"លោកសាក្សី តើមានមូលហេតុអ្វីបានជាធ្វើឱ្យលោកមានការស្ទាក់ស្ទើរក្នុងការផ្ដល់សក្ខីកម្មនៅថ្ងៃនេះ?"* បន្ទាប់មកសាក្សី **ឡុង នរិន្ទ** បានធានាអះអាងថា គាត់មិនមានភាពស្ទាក់ស្ទើរនោះទេ ហើយថាគាត់នឹងឆ្លើយនូវរាល់សំណួរទាំងអស់តាមដែលអាចធ្វើទៅបាន ។ ឆ្លើយតបទៅនឹងការលើកឡើងពីសាក្សីយ៉ាងដូច្នេះ លោក **ដេលី សាក់** បានថ្លែងដូចខាងក្រោមថា៖

> *យើងបានឃើញ [...] នូវភាពស្ទាក់ស្ទើរក្នុងការផ្ដល់សក្ខីកម្ម។ បន្តិចទៀត ខ្ញុំនឹងសួរគាត់នូវចំណុចមួយចំនួនដោយប្រើប្រាស់នូវចម្លើយចេញពីការសម្ភាសន៍របស់គាត់ពីមុន*

*ដែលមិនមានភាពស៊ីចង្វាក់ ជាមួយនឹងអ្វីដែលគាត់កំពុងផ្ដល់សក្ខីកម្មនៅថ្ងៃនេះ ។ ហើយទាក់ទងនឹងការធ្វើដូចនេះ វាពិតជាការពាក់ព័ន្ធមួយដែលយើងត្រូវដឹងថាតើគាត់បានរក្សាទំនាក់ទំនងជាមួយលោក **អៀង សារី** ឬទេបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យចប់ទៅ តើនេះជាហេតុផលនាំឲ្យគាត់ខំការពារលោក **អៀង សារី** ព្រមទាំងមិននិយាយដោយស្មោះត្រង់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងពេលនោះ ។*

ភាគីសហព្រះរាជអាជ្ញាក៏ចាប់ផ្ដើមបន្តសួរលោក **ឡុង នរិន្ទ** អំពីទំនាក់ទំនងរបស់គាត់ជាមួយលោក **អៀង សារី** ។ ជាថ្មីម្ដងទៀត លោក **ឡុង នរិន្ទ** បាននិយាយថា ក្រោយឆ្នាំ១៩៧៩ គាត់មិនដែលមានការប្រាស្រ័យទាក់ទងអ្វីជាមួយនឹងលោក **អៀង សារី** ទេ ។ ទោះជាយ៉ាងនេះក្ដី ព្រះរាជអាជ្ញាបានលើកឡើងថា តាមពិតទៅសាក្សីរូបនេះបានបង្កើតអង្គការមួយឈ្មោះ *"ចលនារួបរួមជាតិប្រជាធិបតេយ្យ"* ជាមួយលោក **អៀង សារី** ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយបានដើរតួនាទីជាអ្នកនាំពាក្យឲ្យលោក **អៀង សារី** ផងដែរ ។ លោកមេធាវី **ម៉ៃឃើល កាណាវាស** និងក្រុមមេធាវីការពារក្ដីអន្តរជាតិរបស់លោក **អៀង សារី** បានជំទាស់នឹងសំណួរបែបនេះ ដោយឈរលើមូលដ្ឋានថាវាជាសំណួរដែលមិនទាក់ទងនឹងសវនាការពេលនេះ ។ លោក **ដេលី សាក់** បានពន្យល់ថា លោកសួរក៏ព្រោះតែសាក្សី **ឡុង នរិន្ទ** បានបង្ហាញពី *"ភាពស្ទាក់ស្ទើរយ៉ាងច្បាស់ក្នុងការផ្ដល់សក្ខីកម្ម"* ហើយក្នុងនាមជាព្រះរាជអាជ្ញាត្រូវតែកំណត់ឲ្យបានថាតើសាក្សីនេះមានទំនាក់ទំនងជាមួយលោក **អៀង សារី** ទេ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្ដួលរំលំ ហើយដើម្បីបានដឹងពីមូលហេតុពិត ឬយ៉ាងណាដែលសាក្សីនេះបានព្យាយាមការពារលោក **អៀង សារី** ព្រមទាំងមិនហ៊ានផ្ដល់ចម្លើយស្មោះត្រង់ទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងអំឡុងរបបនោះ ។ អង្គជំនុំជម្រះសាលាដំបូង មិនបានយល់ស្របនឹងការជំទាស់របស់លោក **កាណាវាស** ទេ ។ ហេតុដូច្នេះហើយធ្វើឲ្យលោក **ដេលី សាក់** ធ្វើការចោទប្រកាន់លើទៅកាន់សាក្សី **ឡុង នរិន្ទ** នៅចំពោះមុខតុលាការ ដោយបានប្រឈមគាត់ (សួរផ្ទុញ) នូវភាពមិនស៊ីចង្វាក់គ្នានៃសេចក្ដីថ្លែងការណ៍ ដែលសាក្សីរូបនេះបានធ្វើជាមួយចៅក្រមស៊ើបអង្កេតកាលពីខែធ្នូ ឆ្នាំ២០០៧ ប្រៀបនឹងចម្លើយក្នុងសក្ខីកម្មបច្ចុប្បន្ន ។ ភាគីសហព្រះរាជអាជ្ញា បានផ្ដោតទៅលើប្រធានបទមួយចំនួន ត្រង់ចំណុចដែលសាក្សីបានលើកឡើងជាច្រើនអំពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យក្នុងបទសម្ភាសន៍មុនៗ ។ ឧទាហរណ៍ នៅក្នុងការសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត លោក **ឡុង នរិន្ទ** បាននិយាយលម្អិតយ៉ាងច្បាស់អំពីសេចក្ដីថ្លែងការណ៍ដោយលោក **អៀង សារី** អំពីបញ្ហាជនក្បត់បង្កប់នៅក្នុងក្រសួងការបរទេស ។ ដូចគ្នានេះដែរ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានទទួលជោគជ័យក្នុងការលាតត្រដាងនូវភាពមិនស៊ីចង្វាក់មួយចំនួនរវាងសក្ខីកម្មរបស់សាក្សី **ឡុង នរិន្ទ** និងចម្លើយរបស់គាត់ពីមុនៗ ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ចំណុចទាំងនេះ អាចជាការធ្វើឲ្យមានការសង្ស័យពីភាពគួរជឿជាក់បានទៅលើសាក្សីរូបនេះ ។ អ្វីដែលបានពិភាក្សាកន្លងទៅនេះ គឺត្រូវពឹងផ្អែកទៅលើអង្គជំនុំជម្រះ ជាអ្នកមាននាទីកំណត់អំពីទម្ងន់ ឬតម្លៃភស្តុតាងទៅលើសក្ខីកម្មរបស់សាក្សី **ឡុង នរិន្ទ** ។

*ជំពូកទី៣ ៖* **បញ្ហាច្បាប់ និងនីតិវិធី**

មានបញ្ហាផ្នែកច្បាប់ និងនីតិវិធីមួយចំនួន ដែលបានបង្កឲ្យមានភាពស្មុគស្មាញខ្លាំងនៅក្នុងដំណើរការនីតិវិធីក្នុងសប្តាហ៍នេះ ។ ភាគីមួយចំនួនបានលើកឡើងអំពីការជំទាស់ និងក្តីបារម្ភទាក់ទងនឹង៖ (ក) វិធានសមស្របក្នុងការអនុញ្ញាតឲ្យសាក្សីគួរបង្ហាញមុខនៅក្នុងតុលាការមុនពេលផ្តល់សក្ខីកម្ម (ខ) តើភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្ម និងបុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញដែលផ្តល់ជំនួយដល់បុគ្គលទាំងនេះនៅពេលពួកគាត់ត្រូវអង្គុយផ្តល់សក្ខីកម្មក្នុងក្រចកសេះ ត្រូវស្បថដែរឬទេ (គ) ប្រសិនបើត្រូវតែស្បថ តើគួរដាក់កំហិតយ៉ាងដូចម្តេចចំពោះការប្រាស្រ័យទាក់ទងគ្នារវាងមេធាវីតំណាងដើមបណ្តឹង និងកូនក្តីរបស់ពួកគេ (ដើមបណ្តឹង) នៅពេលសម្រាកនៃវគ្គសវនាការ ក្នុងអំឡុងពេលដែលដើមបណ្តឹងត្រូវផ្តល់សក្ខីកម្មនោះ (ឃ) តើគួរអនុញ្ញាតឲ្យសាក្សីពិនិត្យមើលឡើងវិញនូវសេចក្តីថ្លែងការណ៍របស់ខ្លួនជាលាយលក្ខណ៍អក្សរដែលបានធ្វើពីមុនមក ដើម្បីជួយរម្លឹកការចងចាំដែរ ឬទេ (ង) សំណួរក្នុងវិសាលភាពដែលអាចអនុញ្ញាតឲ្យសួរដេញដោលបាន ទាក់ទងនឹងសេចក្តីសម្រេចនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី (ច) ទម្រង់សំណួរដែលអនុញ្ញាតឲ្យប្រើនៅក្នុងតុលាការក្នុងការចោទសួរសាក្សី ជាពិសេសថាតើនៅពេលណា ឬក្នុងកាលៈទេសៈអ្វីដែលអនុញ្ញាតឲ្យមានសំណួរនាំមុខបាន និង (ឆ) សិទ្ធិរបស់ជនជាប់ចោទក្នុងការបោះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ ។

## ក. វត្តមានរបស់សាក្សីក្នុងការតាមដានសវនាការ មុនពេលចូលមកផ្តល់សក្ខីកម្ម

លោក **អាង ឧត្តម** មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** បានលើកឡើងអំពីបញ្ហាដែលសាក្សីធ្វើការតាមដានសវនាការមុនពេលចូលខ្លួនមកផ្តល់សក្ខីកម្ម ។ លោកមេធាវីបានសួរថា តើអង្គជំនុំជម្រះសាលាដំបូង ប្រតិបត្តិដូចតុលាការក្នុងស្រុកដទៃទៀតឬយ៉ាងណា ដោយធ្វើការហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលមិនទាន់បានចូលខ្លួនមកផ្តល់សក្ខីកម្មថា មិនឲ្យតាមដានសវនាការ ឬមិនឲ្យទទួលព័ត៌មានអ្វីអំពីដំណើរការនីតិវិធី ។

នេះគឺជារបៀបក្នុងការប្រុងប្រយ័ត្នប្រយែងមួយ ដើម្បីចៀសវាងការជះឥទ្ធិពលមិនសមស្របទៅលើសក្ខីកម្មរបស់សាក្សី ។ សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វត** បានបញ្ជាក់យ៉ាងរហ័សថា វាគួរតែមានការបែងចែកឲ្យច្បាស់រវាងភាគីដើមបណ្តឹង និងសាក្សី ។ លោកស្រីបានពន្យល់ថា ភាគីដើមបណ្តឹងមានសិទ្ធិចូលរួមគ្រប់ដំណើរការនីតិវិធីតុលាការ ។ ក្រោយមកក្នុងថ្ងៃដដែលនោះ លោកប្រធាន **និល ណុន** បានធានាអះអាងថា អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើឲ្យបានល្អបំផុតក្នុងការអនុវត្តតាមវិធានផ្ទៃក្នុង ៨៨(២) ។ វិធានផ្ទៃក្នុង ៨៨(២) ចែងថា៖

*ជនជាប់ចោទមិនត្រូវប្រាស្រ័យទាក់ទងគ្នាទេ ។ ប្រសិនបើអាចធ្វើទៅបាន អ្នកជំនាញ*

*និងសាក្សីត្រូវស្ថិតនៅក្នុងបន្ទប់ផ្សេង ដែលមិនអាចមើលឃើញ ឬឮពីអ្វីដែលប្រព្រឹត្ត ទៅនៅក្នុងបន្ទប់សវនាការទេ ។ នៅពេលស្ថិតក្នុងបន្ទប់នោះ សាក្សីមិនត្រូវប្រាស្រ័យទាក់ទងនឹងគ្នាឡើយ ។*

អង្គជំនុំជម្រះសាលាដំបូង បានណែនាំឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជួយដោះស្រាយបញ្ហានេះឲ្យស៊ីចង្វាក់គ្នាជាមួយនឹងវិធានផ្ទៃក្នុង ៨៨ (២) ក៏ប៉ុន្តែលើសពីនេះទៀត អង្គជំនុំជម្រះបានបញ្ជាក់អំពីភាពគ្មានប្រយោជន៍ក្នុងការបន្តកិច្ចពិភាក្សាអំពីការឃាត់ឃាំងសាក្សីមិនឲ្យតាមដានសវនាការមុនពេលដំណើរការនីតិវិធី ។ លោកប្រធានតុលាការ ចៅក្រម **និល ណុន** បានឲ្យយោបល់ថា តាមការអនុវត្តជាក់ស្តែង ច្បាប់ក្នុងស្រុកមិនអាចអនុវត្តបានទេក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះ ដោយសារតែចារិកលក្ខណៈរបស់ *អ.វ.ត.ក* ។ លោកប្រធានបានលើកហេតុផលថា វាហួសពីសមត្ថភាពរបស់ *អ.វ.ត.ក* ក្នុងការគ្រប់គ្រងបាន អំពីការប្រើប្រាស់មធ្យោបាយទំនាក់ទំនងតាមបែបទំនើបនាពេលបច្ចុប្បន្ននេះ តួយ៉ាងដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងតាមរយៈការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចផ្សេងៗ ។ ចៅក្រម **ឡាវែន៍** បានទាញជាឧទាហរណ៍ថា ជាក់ស្តែងសវនាការពេលនេះ មានអ្នកចូលរួមប្រហែល ៥០០នាក់ ក្នុងសាលសាធារណៈ ហើយ *អ.វ.ត.ក* មិនអាចពិនិត្យ ឬកំណត់អត្តសញ្ញាណរបស់មនុស្សទាំងអស់នោះជារៀងរាល់ថ្ងៃបានទេ ។ អង្គជំនុំជម្រះក៏បានថ្លែងបញ្ជាក់ពីឆន្ទៈក្នុងកិច្ចខិតខំប្រឹងប្រែង *"តាមលទ្ធភាពដែលអាចធ្វើបាន"* ដើម្បីធានាមិនឲ្យមានសាក្សី ឬអ្នកជំនាញណាមួយ មានវត្តមានក្នុងអំឡុងពេលសវនាការមុនពេលចូលខ្លួនមកផ្តល់សក្ខីកម្ម ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះហាក់ដូចជាមិនបង្ហាញឆន្ទៈក្នុងការចេញនូវបទបញ្ជាជាផ្លូវការណាមួយ ឬចាត់វិធានការជាក់លាក់ណាមួយនោះទេ ។ តាមពិតទៅ ចៅក្រម **ឡាវែន៍** បានរម្លឹកទៅដល់ភាគីទាំងអស់ថា នេះមិនមែនជាបទបញ្ញត្តិចាំបាច់ត្រូវតែអនុវត្តនោះទេ ប៉ុន្តែនេះជាភារកិច្ចដែលអង្គភាពគាំពារសាក្សី និង អ្នកជំនាញត្រូវអនុវត្តច្រើនជាង ។

ជាការពិតណាស់ ដែលដំណើរការនីតិវិធីនៅចំពោះមុខ *អ.វ.ត.ក* ត្រូវបានរាយការណ៍ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងប្រព័ន្ធសារព័ត៌មានក្នុងប្រទេសកម្ពុជា ដូចនេះហើយ វាមានការលំបាកខ្លាំងណាស់ ឬស្ទើរតែមិនអាចទៅរួចទេក្នុងការធានាឲ្យបានថាសាក្សីមិនបានតាមដានសវនាការនាពេលកន្លងមក ដោយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយណាមួយនោះ ។ ទោះជាយ៉ាងណាក៏ដោយ គេចង់ដឹងថា តើអង្គជំនុំជម្រះសាលាដំបូងនឹងប្រើវិធីដោះដៃចេញពីប្រតិបត្តិសាជាថ្មី ដោយប្រើប្រាស់គោលការណ៍ចេញពីវិធានផ្ទៃក្នុង៨៨(២) វិញ ព្រោះការពិតទៅលើការទទួលបាននូវព័ត៌មានទាំងឡាយស្តីពីសំណុំរឿង ០០២ គឺវាកាន់តែផ្តល់ភាពភាពងាយស្រួលសម្រាប់សាក្សីប្រាកដមែន ។ វាហាក់ដូចជាកាន់តែសំខាន់ឡើងថែមទៀត ដែលអង្គជំនុំជម្រះគួរតែធ្វើឲ្យបានរៀបរយជាមុន ថាតើគួរមានវិធានការអ្វីខ្លះដែលត្រូវតែយកចិត្តទុកដាក់ពីទង្វើរបស់សាក្សី ដើម្បីត្រៀមមុនការកោះហៅពួកគាត់មកបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការ ដោយមិនចាំបាច់ផ្តោតទៅលើភាពអសមត្ថភាពរបស់អង្គជំនុំជម្រះក្នុងការចេញ

បញ្ជាឲ្យប៉ូលីសប្រព្រឹត្តតាមអនុលោមតាមវិធាននេះ ។ វាកាន់តែមានប្រយោជន៍ថែមទៀត ក្នុងការដែលចៅក្រមត្រូវលើកឡើងនូវគោលការណ៍ដោះស្រាយស្នូលដែលកំពុងមានក្នុងដៃ និងប្រើតួនាទីក្នុងនាមជាអ្នកមានអំណាចចាត់ចែងធ្វើការដាស់តឿនសាក្សីឲ្យបានច្បាស់លាស់ ចៀសវាងមិនឲ្យមើល ឬស្តាប់ការផ្តល់សក្ខីកម្មមុនពេលគាត់ផ្តល់សក្ខីកម្ម ពីព្រោះការធ្វើដូចនេះ គឺដើម្បីទប់ស្កាត់ពួកគេកុំឲ្យទទួលរងឥទ្ធិពលណាមួយដែលត្រូវបានចាត់ទុកថាមិនសមស្រប ។

## ខ. សម្បថដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនួយការក្នុងសាលសវនាការ

បញ្ហានីតិវិធីមួយផ្សេងទៀតដែលក្រុមការពារក្តីបានលើកឡើងក្នុងសប្តាហ៍នេះ គឺបញ្ហានៃការផ្តល់សក្ខីកម្មរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយថាតើអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើដូចម្តេច ទាក់ទងនឹងគុណតម្លៃភស្តុតាងចេញពីពួកគេ ។ នេះជាការសំខាន់សម្រាប់ភាគីទាំងអស់ក្នុងការផ្តល់ការបញ្ជាក់ទៅលើបញ្ហានេះ ដោយសារថា វាអាចបណ្តាលឲ្យមានភាពខុសប្លែកគ្នាយ៉ាងច្រើន ទាក់ទងនឹងវិធីដែលភាគីទាំងឡាយប្រើប្រាស់ក្នុងការសាកសួរលើសាក្សី ។ ជាអកុសល អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមដំណើរការស្តាប់សក្ខីកម្មពីដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ដោយមិនបានធ្វើការបញ្ជាក់អំពីបញ្ហានីតិវិធីនេះឲ្យបានច្បាស់នោះទេ ។

មុនពេលលោក **ក្លាន ហ្វីត** ចាប់ផ្តើមផ្តល់សក្ខីកម្ម លោក **មីឃែល ផិស្តមេន** ដែលជាមេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** បានសួរថាតើដើមបណ្តឹងរដ្ឋប្បវេណីបានស្បថហើយឬនៅ មុនពេលមកដល់បន្ទប់សវនាការនេះ ។ ជាងនេះទៅទៀត លោក **ផិស្តមេន** ចង់ដឹងអំពីវិសាលភាពនៃសក្ខីកម្មដែលតុលាការចង់បានពីដើមបណ្តឹងរូបនេះ ជាពិសេស ថាតើគាត់នឹងផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុ ឬនិយាយតែពីការខូចខាតដែលទទួលបានពីរបបនោះ ។ ការពិតទៅ មិនមានភាគីណាមួយបានដឹងជាមុនឡើយចំពោះបញ្ហានេះ ។ លោកប្រធានអង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបថា ទាំងក្រមព្រហ្មទណ្ឌកម្ពុជា និងទាំងវិធានផ្ទៃក្នុងនៃ *អ.វ.ត.ក* មិនបានតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីស្បថមុនពេលផ្តល់សក្ខីកម្មនោះទេ ដែលនេះវាផ្ទុយពីសាក្សី[6] ។ ដោយការមិនពេញចិត្តនឹងការឆ្លើយតបនោះ មេធាវី **ផិស្តមេន** បានសួរម្តងទៀតថាតើការផ្តល់សក្ខីកម្មរបស់លោក **ក្លាន ហ្វីត** នឹងនិយាយអំពីអង្គហេតុទាក់ទងនឹងបទចោទប្រកាន់ទាំងឡាយលើជនជាប់ចោទ ដែលមានក្នុងដីកាដំណោះស្រាយដែរឬទេ? ឬវាគ្រាន់តែជាការទាមទារសំណងផ្ទាល់ខ្លួនសម្រាប់ការខូចខាត ដែលគាត់បានទទួលរងក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវី **ផិស្តមេន** ពោលអះអាងថាលោក **ក្លាន ហ្វីត** ត្រូវតែស្បថ ប្រសិនបើគាត់ត្រូវផ្តល់សក្ខីកម្មអំពីអង្គហេតុដែលអាចប្រើប្រាស់ដើម្បីគាំទ្រដល់ការផ្តន្ទាទោសទៅលើជនជាប់ចោទ ទោះបីជាទៅលើបទចោទព្រហ្មទណ្ឌបែបណាក៏ដោយ ។

លោក **ពេជ្រ អង្គ** សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានជំទាស់ទៅនឹងសំណួរនេះ ដោយគាត់បានលើកឡើងថា សំណួរនេះមិនសមរម្យទេ ពីព្រោះលោក **ក្លាន ហ្វីត** ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី

គាត់មិនមែនជាសាក្សីនោះទេ ។ ភាពខុសគ្នារវាងភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីសាមញ្ញ គឺថាភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចទាមទារឲ្យមានការគិតគូរពីផលប្រយោជន៍បុគ្គល (សំណង) ចេញពីលទ្ធផលនៃសំណុំរឿងនេះ ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ស្វែងរកការបញ្ជាក់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទសម្រាប់ឧក្រិដ្ឋកម្មដែលបានបណ្តាលឲ្យពួកគាត់ទទួលរងព្យសនកម្ម ។ ការទាមទារសំណងដ៏សមរម្យសម្រាប់ពួកគេ ត្រូវពឹងផ្អែកទៅលើទោសរបស់ជនជាប់ចោទ ។ ផ្ទុយមកវិញ តួនាទីរបស់សាក្សីគឺផ្តល់ព័ត៌មានដល់អង្គជំនុំជម្រះ ដែលព័ត៌មានទាំងនោះ អាចជាការដាក់បន្ទុក និងអាចជាការដោះបន្ទុក ក្នុងការកំណត់នូវភាពមានទោស ឬគ្មានទោសរបស់ជនជាប់ចោទ ។ ដោយបានទទួលស្គាល់ភាពខុសគ្នានេះ លោក **វ៉ាន់ ណាត** ដែលជាអ្នករស់រានមានជីវិតម្នាក់ក្នុងចំណោមប៉ុន្មាននាក់ផ្សេងទៀតពី *មន្ទីរ ស-២១* បានជ្រើសរើសការចូលរួមរបស់ខ្លួនក្នុងនាមជាសាក្សី ជាជាងមាននាទីជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ក្នុងគោលបំណងដើម្បីឲ្យទម្ងន់សក្ខីកម្មរបស់គាត់មានតម្លៃជាភស្តុតាងដែលអាចបញ្ជាក់ទៅលើបទចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

ចៅក្រម **ឡាវែន៍** បានពន្យល់បន្ថែមទៅលើការឆ្លើយជាបឋមរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង តបនឹងសំណួររបស់លោក **ផិស្តមេន** យ៉ាងដូច្នេះថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃដំណើរការនីតិវិធី ហេតុដូច្នេះហើយ ពួកគេអាចផ្តល់សក្ខីកម្មដោយមិនចាំបាច់ស្បថនោះទេ ។ ដើម្បីឲ្យកាន់តែឆ្លើយតបនូវកង្វល់របស់លោក **ផិស្តមេន** ចៅក្រម **ឡាវែន៍** បានបង្ហាញថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់សក្ខីកម្មទាក់ទងនឹងការខូចខាតដែលពួកគេបានទទួលរង ក៏ដូចជាទាក់ទងនឹងអង្គហេតុផងដែរ ។

វាជាការទទួលខុសត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់នៅចុងបញ្ចប់នៃដំណើរការនីតិវិធីអំពីទម្ងន់នៃភស្តុតាងទាញចេញពីសក្ខីកម្មរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលសក្ខីកម្មនោះទាក់ទងនឹងការបង្ហាញនូវចំណងពាក់ព័ន្ធដល់អង្គហេតុ ។ បញ្ហានីតិវិធីមួយទៀតដែលពាក់ព័ន្ធនឹងវត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺថាតើបុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញដែលមកជួយសម្របសម្រួលក្នុងពេលពួកគាត់ផ្តល់សក្ខីកម្មនោះ ត្រូវស្បថដែរឬទេ បើយោងតាមមាត្រា៤៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា ។

លោក **គង់ សំអុន** មេធាវីជាតិការពារក្តីរបស់លោក **ខៀវ សំផន** បានក្រោកឈរឡើងនៅពេលដែលលោក **ភ្លាន ហ្វីត** កំពុងផ្តល់សក្ខីកម្ម និងបានលើកជាសម្អាងថា បុគ្គលិកជំនួយពីអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញ ក៏ត្រូវតែធ្វើសម្បថដែរ ។ លោកប្រធាន **និល ណុន** បានទាត់ចោលនូវកង្វល់បែបនេះ ដោយបានបញ្ជាក់ថា បុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញ មិនបានដើរតួនាទីជាអ្នកបកប្រែផ្លូវការពីភាសាខ្មែរទៅភាសាកាចុកនោះទេ ពួកគាត់គ្រាន់តែជាជំនួយការ ដើម្បីធានាថាលោក **ភ្លាន ហ្វីត** យល់សំណួរដែលបានសួរទៅកាន់រូបគាត់តែប៉ុណ្ណោះ ។ ដោយហេតុថា អ្នកជំនួយមិនមែនជាអ្នកផ្តល់សេវាបកប្រែភាសា ហើយគ្រាន់តែជួយសម្រួលការសាកសួរមកលើលោក **ភ្លាន ហ្វីត** នោះ ប្រធានតុលាការបានសន្និដ្ឋានថា គាត់មិនចាំបាច់ត្រូវធ្វើសម្បថនោះឡើយ ។

## គ. ការប្រាស្រ័យទាក់ទងរវាងភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតំណាងរបស់ខ្លួន

បញ្ហានីតិវិធីចម្រូងចម្រាស់មួយផ្សេងទៀត ដែលត្រូវបានលើកឡើងអំឡុងពេលសវនាការនោះ គឺពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងរវាងមេធាវីប្រឹក្សា និងកូនក្ដីរបស់ខ្លួនក្នុងពេលសម្រាកពីការផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ ។ លោកមេធាវី **កាណាវាស** បានថ្លែងក្រោយពីការសម្រាកវគ្គទីមួយនៃដំណើរការនីតិវិធីថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការ បានធ្វើការពិគ្រោះយោបល់គ្នាជាមួយមេធាវីរបស់ខ្លួនក្នុងពេលសម្រាកសវនាការ ។ លោក **កាណាវាស** បានហៅទង្វើបែបនេះថា *"ជាការមិនសមរម្យ"* ។ គាត់លើកសម្អាងទាក់ទងទៅនឹងដំណើរការជំនុំជម្រះដ៏ត្រឹមត្រូវមួយ គឺថាបុគ្គលដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះសាលាដំបូង មិនថាជាសាក្សី ឬភាគីដើមបណ្ដឹងទេ គឺមិនគួរមានការទាក់ទងអ្វីបន្ថែមជាមួយបុគ្គលណាផ្សេងទៀតជាដាច់ខាត នៅពេលដែលគាត់ចាប់ផ្ដើមផ្ដល់សក្ខីកម្មហើយនោះ ។ គាត់បានទទូចថា ការប្រព្រឹត្តតាមអ្វីដែលគាត់ទើបនឹងលើកឡើង គឺជាការចាំបាច់ណាស់ដើម្បីទប់ស្កាត់កុំឱ្យសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីរងឥទ្ធិពលមិនសមស្របផ្សេងៗ ។ លោកមេធាវី បានសង្កត់ធ្ងន់ថា មេធាវីមិនត្រូវបង្វឹក ឬសូម្បីតែបង្ហាញមុខ ពីព្រោះបើធ្វើដូចនេះទៀត ការជះឥទ្ធិពលណាមួយដល់សក្ខីកម្មរបស់កូនក្ដីខ្លួន គឺជារឿងចៀសមិនរួច ។

សហព្រះរាជអាជ្ញាអន្តរជាតិ លោក **វិល្យៀម ស្មីត** បានយល់ស្របនឹងយោបល់លោក **កាណាវាស** ទាក់ទងនឹងបញ្ហាសាក្សី ។ យោងតាមលោក **ស្មីត** ដើម្បីទប់ស្កាត់កុំឱ្យមានការជះឥទ្ធិពលទៅលើសាក្សីបាន គេត្រូវដាក់កំហិតនូវការប្រាស្រ័យទាក់ទងគ្នារវាងមេធាវី និងសាក្សី ។ ក៏ប៉ុន្តែ លោក **ស្មីត** បានសារភាពថា គាត់ក៏មិនបានដឹងច្បាស់អំពីវិធានច្បាប់របស់បារាំង ឬកម្ពុជា មានខ្លឹមសារយ៉ាងណាស្ដីពីការប្រាស្រ័យទាក់ទងគ្នារវាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតំណាងរបស់ពួកគេ ក្នុងពេលដែលពួកគេផ្ដល់សក្ខីកម្ម ក៏ដូចជាក្នុងអំឡុងពេលសម្រាកនោះ ។

លោកស្រី **អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វូត** សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានលើកសម្អាងថាដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីមិនមែនជាសាក្សី ផ្ទុយទៅវិញគឺជាភាគីមួយក្នុងដំណើរការនីតិវិធីនោះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលបានការអនុញ្ញាតឱ្យប្រឹក្សាជាមួយមេធាវីរបស់ខ្លួន សូម្បីតែនៅក្នុងពេលផ្ដល់សក្ខីកម្មក៏ដោយ ។ សហមេធាវីជាតិនាំមុខ លោក **ពេជ្រ អង្គ** បានស្នើឡើងថា គោលការណ៍ស្មើភាពគ្នានឹងត្រូវបានរំលោភបំពាន ប្រសិនដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យមានសេរីភាពក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីរបស់ខ្លួនគ្រប់ពេលវេលានោះទេ ។ លោក **គីម ម៉េងលី** ដែលជាសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ បានយល់ស្របនឹងមតិរបស់លោក **ពេជ្រ អង្គ** ដោយបានលើកសម្អាងថា ការជំទាស់របស់លោក **កាណាវាស** មិនស្របទៅនឹងការអនុវត្តក្នុងប្រទេសកម្ពុជាឡើយ ហើយអាចនឹងមានឥទ្ធិពលកាត់បន្ថយសិទ្ធិរបស់ភាគីក្នុងការទំនាក់ទំនងជាមួយនឹងមេធាវីរបស់ខ្លួន ។

បន្ទាប់ពីបានស្ដាប់ទឡ្ហីករណ៍របស់ភាគីទាំងឡាយរួចមក អង្គជំនុំជម្រះសាលាដំបូងបានវិនិច្ឆ័យថា តាម

វិធានផ្ទៃក្នុង និងការអនុវត្តច្បាប់ក្នុងប្រទេសកម្ពុជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីក្នុងដំណើរការនីតិវិធី ។ ជាលទ្ធផល ពួកគេទទួលបានសិទ្ធិក្នុងការប្រឹក្សាជាមួយនឹងមេធាវីរបស់ខ្លួននៅគ្រប់ដំណាក់ទាំងអស់នៃនីតិវិធី ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា វិធាន ៨៨(២) អនុវត្តតែទៅលើជនជាប់ចោទ និងសាក្សីតែប៉ុណ្ណោះ ។

## ឃ. ការរម្លឹកការចងចាំរបស់សាក្សីជាមួយនឹងសក្ខីកម្មពីមុនមក

ដើម្បីជំរុញប្រសិទ្ធផលនៃដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សារណៈលេខ E141 និង E141/1 ដោយផ្តល់ឱកាសដល់សាក្សីនានាទទួលបាននូវការសម្របសម្រួលពីអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញឲ្យពួកគាត់អាចរម្លឹកការចងចាំរបស់ខ្លួនមុនពេលផ្តល់សក្ខីកម្ម តាមរយៈការពិនិត្យឡើងវិញនូវសេចក្តីថ្លែងការណ៍ (ចម្លើយ) ទាំងឡាយដែលបានធ្វើឡើងក្នុងដំណាក់កាលស៊ើបអង្កេត[7] ។ មេធាវីការពារក្តីលោក **នួន ជា** បានជំទាស់យ៉ាងដាច់អហង្ការចំពោះការអនុវត្តបែបនេះ ព្រមទាំងបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បង្អកការសម្រេចចិត្តនេះជាបណ្តោះអាសន្ន រង់ចាំដំណោះស្រាយអំពីការជំទាស់នេះចប់សព្វគ្រប់សិន ។

អង្គជំនុំជម្រះសាលាដំបូង តាមរយៈចៅក្រម **ខាតវ៉ាយថ៍** បានបដិសេធការជំទាស់របស់មេធាវីការពារក្តីលោក **នួន ជា** ។ លោកស្រីបានថ្លែងថា អង្គជំនុំជម្រះបានបញ្ជាក់រួចហើយ (នៅក្នុងអនុស្សារណៈលេខ 141/1) ថានឹងមានការផ្តល់ឲ្យសាក្សីនូវឯកសារមួយច្បាប់ ដែលជាចម្លើយសារភាពរបស់ពួកគាត់ក្នុងពេលផ្តល់សម្ភាសន៍ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ។ បន្ថែមលើនេះ ចៅក្រម **ខាតវ៉ាយថ៍** បានពន្យល់ថា ការផ្តល់ឯកសារចម្លើយសារភាពពីមុនដែលគេបានធ្វើក្នុងដំណាក់កាលស៊ើបអង្កេត ជាប្រយោជន៍ជួយសាក្សីដើម្បីរម្លឹកការចងចាំឡើងវិញ ហើយវាជាការអនុវត្តដដែលៗ ។ គាត់បានសង្កត់ធ្ងន់ថា អង្គភាពគាំទ្រសាក្សី និងអ្នកជំនាញ ត្រូវដកយកឯកសារពីមុននោះត្រឡប់មកវិញភ្លាម នៅពេលដែលសាក្សីបានអានឯកសារនោះចប់ ហើយសាក្សីក៏មិនត្រូវអនុញ្ញាតឲ្យយកឯកសារនោះចូលទៅក្នុងតុលាការដែរ ។

## ង. សំណួរនាំមុខ

មានភាពមិនច្បាស់លាស់ទាក់ទងនឹងនីតិវិធីមួយផ្សេងទៀតត្រូវបានលើកយកមកពិភាក្សា រវាងការអនុវត្តទៅលើដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីសាមញ្ញ ។ ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃអង្គារ នៅពេលដែលមេធាវីការពារក្តីលោក **អៀង សារី** បានជំទាស់នឹងសំណួរនាំមុខមួយ ដែលបានចោទសួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ម៉ុច សុវណ្ណារី** ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីលោក **ភ្លាន ហ៊្វីត** ។ លោក **កាណាវ៉ាស** បានជំទាស់ដោយឈរលើហេតុផលថាសំណួររបស់មេធាវី **សុវណ្ណារី** មានបំណងនាំដើមបណ្តឹងរដ្ឋប្បវេណីឲ្យផ្តល់នូវចម្លើយដែលខ្លួនឯងចង់បាន ។ ប្រធានអង្គជំនុំជម្រះបានយល់ស្របនឹងការជំទាស់នោះ ។ បន្ទាប់មក លោក

**កាណាវាស** បានធ្វើការជំទាស់ស្រដៀងគ្នានេះមួយទៀត ក្រោយពីមេធាវី **ម៉ុច សុវណ្ណារី** ដដែលរូបនេះ បានសួរដល់ *"គោលនយោបាយប្រឆាំងវៀតណាម"* ដែលលោក **ក្អួន ហ៊ឿត** មិនបាននិយាយពីដើមដំបូងក្នុងពេលកំពុងតែផ្តល់សក្ខីកម្មរបស់គាត់នោះទេ ។ លោក **កាណាវាស** បានពណ៌នាសំណួរនោះថា *"ជាវិធីដឹកមុខសាក្សីដ៏ចាស់គម្រិលមួយ"* ។ គាត់និយាយបន្ថែមទៀតថា សំណួរត្រូវកំណត់ក្នុងខ្លឹមសារគន្លឹះអំពី *"អ្នកណា យ៉ាងម៉េច ហេតុអ្វី ពេលណា សូមពន្យល់ និងសូមរៀបរាប់"* ហើយមិនត្រូវនិយាយអ្វីដែលនាំទៅរកចម្លើយដែលអ្នកសួរចង់បាននោះទេ ។ លោកប្រធានតុលាការ ចៅក្រម **និល ណុន** បានបដិសេធការជំទាស់នេះ ដោយឈរលើហេតុផលថា សំណួរនោះចេញពីអង្គហេតុដែលបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ ។ លោក **អាថឺ វែកកែន** មេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ **ខៀវ សំផន** បានជំទាស់នឹងការសម្រេចនោះ ។ គាត់លើកសម្អាងថា ដីកាដំណោះស្រាយមិនបង្កើតជាអង្គហេតុនោះទេ ។ ដូចគ្នានឹងវិធីបដិសេធនូវការជំទាស់ជាមួយក្រុមមេធាវីការពារក្តីជាច្រើនទៀតដែរ ទាក់ទងនឹងបញ្ហានីតិវិធីនេះ លោកប្រធាន **និល ណុន** បានទាត់ចោលនូវទឡ្ហីករណ៍របស់មេធាវី **វែកកែន** ដោយមិនបានលើកឡើងនូវមូលដ្ឋានអ្វីនាំឲ្យមានការជាបដិសេធនោះឡើយ ។ ផ្ទុយមកវិញ លោកចៅក្រមបានបដិសេធលើការជំទាស់នេះទាំងស្រុង ដោយសង្កត់ធ្ងន់ថា ការជំទាស់នោះ *"ឥតខ្លឹមសារ"* និងគ្មានគោលបំណងជាក់លាក់ និងថែមទាំងបានបន្ថែមថា ការលើកឡើងរបស់លោក **វែកកែន** "គ្រាន់តែជាការរំខានដល់ដំណើរការនីតិវិធីតែប៉ុណ្ណោះ" ។

ដោយសារតែអង្គជំនុំជម្រះសាលាដំបូង មិនបានបង្ហាញពីភាពមិនស៊ីចង្វាក់គ្នាក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងសំណួរនាំមុខ ក៏ដូចជាការខកខានមិនបានប្រកាសអំពីនីតិវិធីច្បាស់លាស់មួយ នូវអ្វីដែលអាចទទួលយកបាន និងអ្វីដែលមិនអាចទទួលយកបាន ទាក់ទងនឹងបញ្ហារវាងសាក្សីជាដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីសាមញ្ញនោះ ។ ប្រការនេះ បានធ្វើឲ្យមានការចោទសួរអំពីភាពសមរម្យក្នុងការសួរសំណួរនាំមុខ ហើយវាត្រូវបានកើតឡើងពេញដំណើរការនីតិវិធីដោយចៀសមិនរួច ។ បញ្ហាដដែលៗនេះ ត្រូវបានលើកឡើងជាច្រើនដងនៅក្នុងសំណុំរឿង០០១ ដោយគ្មានដំណោះស្រាយច្បាស់លាស់ពីអង្គជំនុំជម្រះឡើយ ។ ការភាន់ច្រឡំមួយចំនួន ទំនងជាកើតចេញមកពីការអនុវត្តច្បាប់ក្នុងប្រព័ន្ធជាតិផ្សេងៗគ្នារបស់មេធាវីចម្រុះជាតិសាសន៍នៃ *អ.វ.ត.ក* ។ ខុសពីគោលការណ៍នីតិវិធីចំពោះមុខនៅក្នុង*ប្រព័ន្ធច្បាប់កុម្ម៉ុនឡូ (common law)* សាក្សីទាំងអស់នៅ *អ.វ.ត.ក* ជាសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង គឺមិនមែនជាសាក្សីរបស់ភាគីណាមួយឡើយ (សាក្សីស្នើដោយព្រះរាជអាជ្ញា ឬសាក្សីស្នើដោយក្រុមការពារក្តី) មិនសំខាន់ថា ភាគីណាជាអ្នកបញ្ចូលឈ្មោះសាក្សីណាមួយចូលក្នុងបញ្ជីសាក្សីរបស់ខ្លួននោះទេ ។ សាក្សីត្រូវបានកោះហៅដោយអង្គជំនុំជម្រះសាលាដំបូង គឺមិនមែនកោះហៅដោយភាគីឡើយ បើយោងតាមវិធាន ៨៧.៤ ។

បើគិតអំពីការច្របាច់បញ្ចូលគ្នារវាងការអនុវត្តគោលការណ៍ចំពោះមុខ និងគោលការណ៍សួរដេញដោលដោយចៅក្រមដែល *អ.វ.ត.ក* ដែលបានអនុម័តក្រោមវិធាន២១.១(ក) វាជាការល្អសម្រាប់អង្គជំនុំជម្រះក្នុងការ

កំណត់អំពីចំណុចដែលមានការភាន់ច្រឡំផ្នែកនីតិវិធី និងបញ្ជាក់ឲ្យច្បាស់អំពីការរំពឹងទុកដ៏សមហេតុផលមួយដល់ភាគីឲ្យបានកាន់តែឆាប់កាន់តែល្អ ពោលគឺតាំងពីការចាប់ដំណើរការនីតិវិធីពីដំបូងមកម្ល៉េះ ។ ការធ្វើបែបនេះ អាចជួយធ្វើឲ្យផលមិនល្អមានកម្រិតជាអប្បរមា និងចៀសវាងបាននូវការជំទាស់ដដែលៗ ដោយសារគ្មានការទប់ស្កាត់ពីដំបូងទី ។ ជាអកុសល រហូតមកទល់ពេលនេះ មិនទាន់មានដំណោះស្រាយណាមួយឡើយចំពោះបញ្ហាទាំងអស់នេះ ។ ទោះបីជាគេអាចមើលឃើញថា អង្គជំនុំជម្រះ នឹងវិនិច្ឆ័យទៅលើការជំទាស់ទាំងនេះម្តងមួយករណីៗក៏ដោយ ក៏គេនៅតែយល់ថា វាអាចផ្តល់ប្រយោជន៍ច្រើន ប្រសិនបើអង្គជំនុំជម្រះបានផ្តល់ឲ្យភាគីទាំងអស់នូវគោលការណ៍ណែនាំជាមូលដ្ឋានមួយ នៅពេលបញ្ហាទាំងនេះបានកើតឡើង ឬក្នុងអំឡុងពេលមានកិច្ចប្រជុំគ្រប់គ្រងការជំនុំជម្រះ ។

## ច. កម្មវត្ថុនៃការចោទសួរ លើកលែងវិសាលភាពនៃផ្នែកទីមួយនៃសំណុំរឿង០០២

ទាក់ទងនឹងវិសាលភាពដែលអាចអនុញ្ញាតបានសម្រាប់ការចោទសួរសាក្សីនេះ គឺនៅមានភាពខ្វះខាតក្នុងការបញ្ជាក់ឲ្យបានច្បាស់ជាច្រើន ដែលកើតចេញមកពីដីកាបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ។ ជាថ្មីម្តងទៀត ភាពគ្មានឆន្ទៈរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដើរតួនាទីធ្វើឲ្យមានការផ្លាស់ប្តូរ ដោយធ្វើការបញ្ជាក់ និងដោះស្រាយបញ្ហាឲ្យបានច្បាស់លាស់ បានបង្កឲ្យមានការភាន់ច្រឡំកំប៉ិកកំប៉ុកជាច្រើនក្នុងសវនាការនីតិវិធី ។

ក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី[8] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ចេញជាករណីតូចៗ ដែលបញ្ចូលការចោទប្រកាន់លើអង្គហេតុជាក់លាក់ និងបញ្ហាផ្នែកច្បាប់ ដូចខាងក្រោម៖

១. រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ

២. តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗបានទទួលការចាត់តាំងនូវតួនាទីទាំងនោះ។

៣. តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាល ការទទួលខុសត្រូវរបស់ពួកគេតាមរយៈការចាត់តាំងក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលវែងដែលពាក់ព័ន្ធនឹងយុត្តាធិការតាមពេលវេលារបស់ *អ.វ.ត.ក* ។

៤. គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

៥. ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងការជម្លៀស និងការផ្លាស់លំនៅដ្ឋានប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ហើយនិង

៦. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដោយហេតុថា អង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)[9]។

ដូចនេះមានន័យថា រាល់សំណួរដែលត្រូវសួរដេញដោលនៅក្នុងការជំនុំជម្រះក្នុងវគ្គទីមួយ ត្រូវតែទាក់ទងតែជាមួយនឹងអង្គហេតុដែលបានចែងដូចខាងលើតែប៉ុណ្ណោះ ។ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថានៅក្នុង *"កាលៈទេសៈពិសេស"* អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យភាគីទាំងឡាយសួរសំណួរហួសពីបញ្ហាក្នុងវគ្គទីមួយនៃការជំនុំជម្រះនេះបាន ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលសហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ស៊ីម៉ូណូ ហ្វត** ស្នើឲ្យប្រធានអង្គជំនុំជម្រះ ចៅក្រម **និល ណុន** បញ្ជាក់ឲ្យបានច្បាស់អំពីអ្វីទៅជា *"កាលៈទេសៈពិសេស"* នោះ? លោកប្រធានបែរជាប្រាប់ឲ្យលោកស្រីឲ្យយោងទៅលើដីកាបំបែកកិច្ចដំណើរការ និងបានរម្លឹកដល់ភាគីទាំងឡាយ ឲ្យកំហិតសំណួររបស់ខ្លួនតែទៅលើបញ្ហាដែលទាក់ទងនឹងផ្នែកទីមួយបានហើយ ។ ដោយមានការមិនពេញចិត្តនឹងការឆ្លើយតបនេះលោកស្រី **ស៊ីម៉ូណូ ហ្វត** បានសួរថា តើអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យភាគីទាំងឡាយសួរលោក **ភួន ហ្វៀត** នូវសំណួរក្រៅពីកម្មវត្ថុនៃផ្នែកទីមួយនៃការជំនុំជម្រះដែរឬទេ ។ អង្គជំនុំជម្រះបានជម្រាបសហមេធាវីអន្តរជាតិនាំមុខរូបនេះថា អង្គជំនុំជម្រះសាលាដំបូង *"ភាគច្រើននឹង"* បដិសេធនូវសំណូមពរនេះ ។ ភាគីសហព្រះរាជអាជ្ញា បានលើកឡើងនូវបញ្ហាដដែលនេះ និងបានសួរទៅកាន់អង្គជំនុំជម្រះ ថាតើ *"ហេតុផលពិសេស"* មានន័យយ៉ាងដូចម្តេច ពីព្រោះកាលណាភាគីបានយល់ច្បាស់ វាអាចនឹងជួយឲ្យពួកគាត់បានត្រៀមនូវសំណូមពរមួយដែលអង្គជំនុំជម្រះសាលាដំបូងអាចនឹងពិចារណា ។ ជាការឆ្លើយតប លោកប្រធាន **និល ណុន** បានស្នើឲ្យព្រះរាជអាជ្ញាមើលលើឯកសាររបស់តុលាការលេខ 124/7.1/Corr.2[10] និងបានបន្តពន្យល់ថា ប្រសិនបើភាគីចង់ពិភាក្សាប្រធានបទហួសអំពីវិសាលភាពនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី ភាគីត្រូវដាក់សំណូមពរដែលមានការពន្យល់ហេតុផលជាមុនដល់អង្គជំនុំជម្រះ ។

ភាគីសហព្រះរាជអាជ្ញា ក៏បាននិយាយអំពីបញ្ហានេះម្តងទៀតនៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក **វីនសិន ដឺវ៉ាល់** សួរថា តើគាត់អាចចោទសួរលោក **ឡុង នរិន្ទ** នូវសំណុំរឿង០០២ ទាំងស្រុងបានដែរឬទេ គឺមិនមែនត្រឹមតែផ្នែកទីមួយនៃការជំនុំជម្រះនេះឡើយ ។ ព្រះរាជអាជ្ញាបានលើកជាសម្អាងថា *"ស្ថានភាពសុខភាពមិនទៀងទាត់"* របស់សាក្សី **ឡុង នរិន្ទ** គឺជាហេតុផលពិសេសមួយ ដែលទំនងជាមិនអាចឲ្យគាត់បានវិលត្រឡប់មកផ្តល់សក្ខីកម្មនៅពេលក្រោយម្តងទៀតបានទេ ។ ដូចនេះ ភាគីសហព្រះរាជអាជ្ញា គួរត្រូវបានអនុញ្ញាតឲ្យសួរសាក្សីរូបនេះ អំពីគ្រប់បទចោទប្រកាន់ទាំងអស់នៅក្នុងដីកាដំណោះស្រាយ ។ លោក **កាណាវាស** បានជំទាស់នឹងការស្នើនេះ ដោយបានសង្កត់ធ្ងន់ថា ការស្នើបែបនេះ គួរតែធ្វើក្នុងពេលវេលាសមគួរណាមួយ មុនពេលសវនាការចាប់ផ្តើម ហើយគួរតែផ្តល់នូវភាពជាក់លាក់ឲ្យបានច្រើនជាងនេះ ដូចជាថាតើចំណុចអ្វីខ្លះដែលខ្លួនចង់ទាមទារឲ្យ

អង្គជំនុំជម្រះពិចារណា ។ មេធាវីបានទទូចថា ភាគីដទៃទៀត គួរត្រូវបានអនុញ្ញាតឲ្យឆ្លើយតបនឹងការទាមទារអំពី *"កាលៈទេសៈពិសេស"* ។

អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របតាមការស្នើរបស់ភាគីសហព្រះរាជអាជ្ញា ទៅលើបញ្ហាដែលកំពុងកើតមាននោះ គឺអនុញ្ញាតឲ្យសួរលោក **ឡុង នរិន្ទ** ទៅលើគ្រប់ទិដ្ឋភាពទាំងអស់ក្នុងសំណុំរឿង០០២ ។ អង្គជំនុំជម្រះ មិនបានដោះស្រាយនូវក្ដីបារម្ភអំពីនីតិវិធីទូលំទូលាយ ថាតើអង្គជំនុំជម្រះនឹងដោះស្រាយយ៉ាងណាចំពោះសវនាការបន្តបន្ទាប់ ក៏ដូចជាការឆ្លើយតបទៅនឹងខ្លឹមសារនៃការទាមទារក្នុង *"កាលៈទេសៈពិសេស"* នោះទេ ។

ក្រុមមេធាវីការពារក្ដីលោក **នួន ជា** បានលើកឡើងនូវការជំទាស់ជាក់លាក់មួយចំនួនចំពោះវិសាលភាពនៃការសួរដេញដោល យ៉ាងហោចណាស់ពីរដង ក្នុងពេលដែលសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរទៅកាន់លោក **ក្លាន ហ្វីត** និងការឆ្លើយតបមិនស៊ីចង្វាក់គ្នាទាំងស្រុងរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងការជំទាស់ទាំងនេះ រីឯហេតុផលពីក្រោយការវិនិច្ឆ័យក៏មិនមានភាពច្បាស់លាស់ដែរ។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី **ម៉ុច សុវណ្ណារី** បានសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីថា *"បន្ទាប់ពីខ្មែរក្រហមរំដោះក្រុងភ្នំពេញបានក្នុងខែមេសា ឆ្នាំ១៩៧៥ តើលោកត្រូវបានគេអញ្ជើញឲ្យមកទទួលវគ្គបណ្ដុះបណ្ដាលនយោបាយនៅក្រុងភ្នំពេញដែរឬទេ?"* ហើយក្រោយៗមកទៀត លោកស្រីបានសួរសំណួរដេញមួយចំនួនទៀតលើប្រធានបទនេះ ។ លោក **ផិស្ដ មេន** បានជំទាស់លើមូលដ្ឋានដែលថាសំណួរទាំងនោះមិនទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះផ្នែកនេះ ។ អង្គជំនុំជម្រះបានបដិសេធនឹងការជំទាស់របស់មេធាវី **ផិស្ដមេន** និងបានសម្រេចថា ដោយសារតែសំណួររបស់មេធាវី **ម៉ុច សុវណ្ណារី** ជាប់ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា ដូច្នេះ សំណួរទាំងនេះស្ថិតនៅក្នុងវិសាលភាពនៃដីកាបំបែកកិច្ចដំណើរការ ។ បន្ទាប់មកទៀត ការចោទសួររបស់មេធាវី **ម៉ុច សុវណ្ណារី** បានសួរដល់តួនាទីរបស់លោក **ក្លាន ហ្វីត** *"បន្ទាប់ពីការរំដោះបានទីក្រុងភ្នំពេញ"* ។ បន្ទាប់ពីលោក **ក្លាន ហ្វីត** បានឆ្លើយថាគាត់ជាលេខារងនៃ*ស្រុក២១* ក្នុង*តំបន់លេខ១០១* សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តសួរសំណួរទាក់ទងនឹងរចនាសម្ព័ន្ធ និងបុគ្គលិកមួយចំនួនទៀតដែលមានតួនាទីនៅក្នុងភូមិភាគឧត្ដរ និងព្លសាន ។ លោក **ផិស្ដមេន** បានជំទាស់ទៅនឹងសំណួរទាំងនេះលើហេតុផលដដែលថា មិនមានការទាក់ទងនឹងសវនាការក្នុងវគ្គទី១ ។ អង្គជំនុំជម្រះ យល់ស្របនឹងការជំទាស់លើកទីពីរនេះ និងបានរម្លឹកលោកស្រី **ម៉ុច សុវណ្ណារី** ថាសំណួរគួរតែកំហិតត្រឹមកម្មវត្ថុដែលមានគ្របដណ្ដប់លើផ្នែកទីមួយនៃការជំនុំជម្រះនេះទៅបានហើយ ។

គេមិនដឹងច្បាស់ទាល់តែសោះថា ហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងបានបដិសេធការជំទាស់របស់លោក **ផិស្ដមេន** ចំពោះសំណួរទាក់ទងនឹងវគ្គបណ្ដុះបណ្ដាលនយោបាយធ្វើនៅភ្នំពេញ ប៉ុន្តែបែរជាបានយល់ស្របនឹងការជំទាស់មួយផ្សេងទៀតដែលសួរទាក់ទងនឹងតួនាទីរបស់លោក **ក្លាន ហ្វីត** និងកម្មាភិបាលផ្សេងៗទៀតទៅវិញ ក្នុងខណៈដែលសំណួរទាំងអស់នេះបានគ្របដណ្ដប់នូវព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយឆ្នាំ១៩៧៥ ។ យោងតាមកាលៈទេសៈទាំងនេះ វិសាលភាពនៃសំណួរដែលអាចអនុញ្ញាតឲ្យសួរបាន ឬមិនបានទៅលើសាក្សី និង

ដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានភាពមិនច្បាស់លាស់ដដែល ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនចាត់វិធានការ ដោយធ្វើការបញ្ជាក់លើបញ្ហាទាំងនេះឲ្យបានច្បាស់ទេនោះ យើងរំពឹងថាភាគីទាំងឡាយនឹងបន្តការអនុវត្តនូវរបៀបមួយ ដែលគ្មានគោលការណ៍ណែនាំច្បាស់លាស់ លើសពីនេះទៀត ភាគីទាំងឡាយនឹងនៅតែបន្តលើកឡើងនូវសំណូមពរ និងការជំទាស់ដដែលៗលើបញ្ហានេះ ។ ជាអកុសល បញ្ហានេះនឹងចំណាយពេលវេលារបស់តុលាការកាន់តែច្រើន បើទោះជាវាមិនមានភាពចាំបាច់ទាល់តែសោះ ចំពោះការជជែកពិភាក្សាលើបញ្ហានីតិវិធីទាំងដូចបានលើកឡើងកន្លងមក ដែលតាមពិតទៅពេលវេលាខ្លះខ្ជាយទាំងនេះ អាចនឹងត្រូវលៃយកទៅប្រើប្រាស់បានលើការវាយតម្លៃភស្តុតាងសំខាន់ៗ ។

## ឆ. សិទ្ធិជនជាប់ចោទក្នុងការបោះបង់សិទ្ធិមិនបង្ហាញខ្លួនក្នុងសាលសវនាការ

សិទ្ធិជនជាប់ចោទក្នុងការបោះបង់សិទ្ធិមិនបង្ហាញខ្លួនក្នុងសាលសវនាការ ក្នុងពេលជំនុំជម្រះរឿងក្តីរបស់ពួកគាត់ ត្រូវបានគេលើកយកពិភាក្សាម្តងទៀត ក្នុងអំឡុងពេលពីរថ្ងៃដំបូងនៃសវនាការលើភស្តុតាង ។ លោក **នួន ជា** បានសុំអនុញ្ញាតពីអង្គជំនុំជម្រះជាញឹកញាប់ ដើម្បីឲ្យគាត់វិលទៅសម្រាកនៅបន្ទប់ឃុំឃាំងវិញ ព្រោះគាត់មានអាការៈហត់ហេវខ្លាំងពេក ហើយមានការឡើងសម្ពាធឈាមផងដែរ ។ នៅរសៀលថ្ងៃដំបូង លោកប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យលោក **នួន ជា** បន្តការផ្តល់សក្ខីកម្ម៣០នាទីទៀត ក្នុងគោលបំណងដើម្បីរក្សាឲ្យមានលំហូរនៃដំណើរការនីតិវិធីបានរលូន ។ ក៏ប៉ុន្តែនៅថ្ងៃទីពីរបន្ទាប់ពីការសម្រាកពេលព្រឹក លោក **នួន ជា** បានទទូចថាគាត់មិនអាចបន្តផ្តល់ចម្លើយឲ្យបានត្រឹមត្រូវ និងមានន័យបានទេ ដោយសារតែលក្ខខណ្ឌសុខភាពរបស់គាត់ ។ ដោយពឹងផ្អែកលើរបាយការណ៍វេជ្ជសាស្ត្រពីវេជ្ជបណ្ឌិតបំពេញភារកិច្ចក្នុងសាលសវនាការ លោកប្រធាន **និល ណុន** បានបដិសេធសំណូមពររបស់លោក **នួន ជា** មិនឲ្យគាត់វិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញទេ ប៉ុន្តែបានបញ្ជាឲ្យគេនាំជនជាប់ចោទរូបនេះទៅកាន់បន្ទប់សោតទស្សន៍ទៅវិញ (បន្ទប់ឃុំឃាំងតែមានភ្ជាប់វីដេអូពីបន្ទប់សវនាការ) ។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាឲ្យមន្ត្រីសន្តិសុខនាំខ្លួនលោក **នួន ជា** ត្រឡប់មកសាលសវនាការវិញ បន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់ ។ លោក **អាន់ឌ្រូ អៀនូហ្ស៊ី** មេធាវីការពារក្តីអន្តរជាតិរបស់លោក **នួន ជា** បានលើកឡើងថា មិនភាពចាំបាច់ណាមួយដែលត្រូវគេបង្ខំឲ្យកូនក្តីរបស់គាត់ចូលរួមតាមដានសវនាការនោះទេ ពីព្រោះគាត់បានបោះបង់សិទ្ធិមិនបង្ហាញខ្លួនរួចហើយ ។ ទោះជាយ៉ាងណាក៏ដោយ លោក **អៀនូហ្ស៊ី** មិនបានទទួលជោគជ័យក្នុងការអូសទាញអង្គជំនុំជម្រះសាលាដំបូងឲ្យអនុញ្ញាតឲ្យកូនក្តីរបស់គាត់ត្រឡប់ទៅមន្ទីរឃុំឃាំងវិញនោះទេ[11]។ អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់សញ្ញាណាមួយថាតើការវិនិច្ឆ័យបែបនេះនឹងក្លាយទៅជាបទដ្ឋាននៃនីតិវិធីនៅពេលជនជាប់ចោទណាម្នាក់ស្នើសុំអនុញ្ញាតត្រឡប់ទៅវិញនោះឬយ៉ាងណានោះទេ ។ មានតែពេលវេលាប៉ុណ្ណោះដែលអាចដឹងបាន ។

ជាវិធានទូទៅ មានការតម្រូវជាមូលដ្ឋានថាជនជាប់ចោទត្រូវមានវត្តមាននៅក្នុងការជំនុំជម្រះទៅលើរឿង

ក្តីរបស់ខ្លួន ។ ប្រសិនបើជនជាប់ចោទ មិនអាចចូលរួមដោយសារហេតុផលសុខភាពផ្លូវកាយ ឬផ្លូវចិត្តនោះ វានឹងទាមទារឲ្យតុលាការត្រូវតែទទួលបាននូវភស្តុតាងពីអ្នកជំនាញ ដើម្បីបញ្ជាក់ពីមូលហេតុនៃអវត្តមានរបស់ជនជាប់ចោទ[12] ។ យុត្តាធិការក្នុងស្រុកមួយចំនួន រួមមានទាំងនៅកម្ពុជា[13] បារាំង[14] និង សហរដ្ឋអាមេរិក[15] គឺតម្រូវឲ្យជនជាប់ចោទបង្ហាញខ្លួនក្នុងអំឡុងពេលជំនុំជម្រះក្តីរបស់ខ្លួន ប៉ុន្តែអាចបោះបង់សិទ្ធិបង្ហាញខ្លួននៅក្នុងកាលៈទេសៈមួយចំនួន ជាពិសេស នៅពេលដែលជនជាប់ចោទមានការបារម្ភអំពីបញ្ហាសុខភាព ។

តម្រូវការនៃវិធាន៨១.១ នៃ *អ.វ.ត.ក* បានបញ្ជាក់ថា ជនជាប់ចោទដែលត្រូវធ្វើការជំនុំជម្រះ គឺត្រូវតែមានវត្តមានរបស់គាត់ចូលរួមផ្ទាល់ ។ ប៉ុន្តែ វិធាន៨១.៥ បានផ្តល់ការលើកលែងមួយចំនួន ដោយសារមូលហេតុសុខភាព ឬការបារម្ភធ្ងន់ធ្ងរផ្សេងៗទៀត ។ ក្រោមវិធាននេះ អង្គជំនុំជម្រះសាលាដំបូង អាចបន្តដំណើរការនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទក៏បាន តែត្រូវមានការព្រមព្រៀងពីជនជាប់ចោទជាមុនសិន ។ ចំពោះការដែលជនជាប់ចោទបោះបង់សិទ្ធិមិនបង្ហាញវត្តមាន អង្គជំនុំជម្រះបានបញ្ជាឲ្យជនជាប់ចោទតាមរយៈមេធាវីខ្លួនត្រូវដាក់លិខិតសំណូមពរជាផ្លូវការជាមុនសិន ។ ការធ្វើដូចនេះ គឺដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើការសម្រេចចិត្តផ្អែកលើសេចក្តីជូនដំណឹងជាមុននេះ[16] ។ នៅពេលដែលអវត្តមានរបស់ជនជាប់ចោទអាចបណ្តាលឲ្យមានពន្យារពេលច្រើននៅក្នុងដំណើរការនីតិវិធី និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌ជារឿងចាំបាច់នោះ វិធាន៨១.៥ អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីបង្គាប់បញ្ជាមួយដាច់ខាត ដែលតម្រូវឲ្យមានការចូលរួមពីជនជាប់ចោទទោះជាត្រូវធ្វើតាមរយៈមធ្យោបាយដែលអនុញ្ញាតឲ្យជនជាប់ចោទអាចតាមដានសវនាការខ្លួនពីបន្ទប់សោតទស្សន៍ក៏ដោយ ។ លើសពីនេះទៀត វិធាន៨១.៤ បានលើកឡើងថា ដំណើរការនីតិវិធីនៅតែអាចបន្តក្រោយពេលជនជាប់ចោទបានបង្ហាញខ្លួនក្នុងកិច្ចដំណើរការនីតិវិធីលើកដំបូង បើទោះជាគាត់ ក្រោយមកទៀតបន្តបដិសេធមិនចូលរួម ឬខកខានមិនបានចូលរួមកិច្ចដំណើរការនីតិវិធី ឬក៏គាត់ត្រូវបានបណ្តេញចេញទាំងស្រុងពីកិច្ចដំណើរការនីតិវិធីក៏ដោយ ។ ក្នុងករណីទាំងនេះ ជនជាប់ចោទអាចត្រូវបានការពារក្តីរបស់ខ្លួនតាមរយៈមេធាវី ។ តាមបទបញ្ញត្តិទាំងនេះ ទោះបីជាវិធានទូទៅតម្រូវឲ្យមានវត្តមានរបស់ជនជាប់ចោទក្នុងដំណើរការនីតិវិធីក៏ដោយ ក៏មិនមែនមានន័យថាជនជាប់ចោទត្រូវតែបង្ហាញខ្លួនក្នុងបន្ទប់សវនាការគ្រប់កាលៈទេសៈដែរ ដរាបណាមេធាវីតំណាងជនជាប់ចោទរូបនោះ មានវត្តមានការពាររឿងក្តីឲ្យកូនក្តីខ្លួននៅក្នុងដំណើរការនីតិវិធី ។

## *ជំពូកទី៤ ៖* ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ការការពារ និងការគាំទ្រដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

ពេញមួយសប្តាហ៍នេះ យ៉ាងហោចណាស់ដើមបណ្តឹងរដ្ឋប្បវេណី១០នាក់ បានអង្គុយតាមដានដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការ ។ ភាគីដើមបណ្តឹងដទៃទៀត បានចូលរួមតាមដានពីសាលសាធារណជន ។

## ក. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមាននាទីសួរសំណួរទៅកាន់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមុនគេ

ដើម្បីសម្រួលការចោទសួរ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដឹកនាំការចោទសួរដើមបណ្តឹងរដ្ឋប្បវេណីពីររូបដែលបានផ្តល់សក្ខីកម្មក្នុងដំណើរការនីតិវិធីនាសប្តាហ៍នេះ មុនភាគីផ្សេងទៀត ។ ការធ្វើបែបនេះ បាននាំឲ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើរតួនាទីយ៉ាងសកម្មដើម្បីនាំផ្លូវការចោទសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរ ។ វាក៏បានផ្តល់នូវវិធានការក្នុងការទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមរបស់ភាគីដើមបណ្តឹងក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះផងដែរ ។

## ខ. សំណួរច្រំដែល និងមិនពាក់ព័ន្ធ

អ្នកសរសេររបាយការណ៍ឃ្លាំមើលដំណើរការនីតិវិធីរបស់ *អ.វ.ត.ក* សម្រាប់របាយការណ៍មួយនេះ បានសង្កេតឃើញថានៅពេលដើមបណ្តឹងរដ្ឋប្បវេណីកំពុងផ្តល់សក្ខីកម្ម សំណួរមួយចំនួនដែលចោទឡើងដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅលើកូនក្តីរបស់ខ្លួនហាក់ដូចជាច្រំដែល និងមិនពាក់ព័ន្ធទៅនឹងវិសាលភាពក្នុងផ្នែកនៃការជំនុំជម្រះវគ្គនេះ ។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់យោបល់ថា លោកស្រី **ម៉ុច សុវណ្ណារី** ហាក់ដូចជាមិនបានប្រើពេលវេលាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យក្នុងការចោទសួរនេះឲ្យមានប្រយោជន៍នោះទេ ។ ចំណុចនេះ បានជះផលអវិជ្ជមានក្នុងការបែងចែកពេលវេលាដល់ភាគីដទៃទៀតសម្រាប់សួរដេញដោល ក្នុងរយៈពេលមួយសប្តាហ៍នេះ ។

## គ. ការគាំទ្រសាក្សី និងជនរងគ្រោះ

ទោះបីជាមិនមានអ្នកបកប្រែអាជីពសម្រាប់ដើមបណ្តឹងទាំងពីររូប (ជនជាតិភាគតិចកាចុក) ដែលបានផ្តល់សក្ខីកម្មនៅសប្តាហ៍នេះក្តី ក៏អង្គជំនុំជម្រះសាលាដំបូងបានខិតខំប្រឹងប្រែងផ្តល់ការគាំទ្រតាមដែលអាចធ្វើទៅបានដោយអនុញ្ញាតឲ្យមានបុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញនៅអមជាមួយដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះ ព្រមទាំងជួយសម្របសម្រួលដល់ពួកគាត់ ធ្វើយ៉ាងណាឲ្យយល់នូវសំណួរទាំងឡាយដែលបានសួរក្នុងអំឡុងពេលផ្តល់សក្ខីកម្ម ។ បុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញទាំងនេះ បានថាតាម និងបញ្ជាក់ឡើងវិញនូវសំណួរដែលបានចោទសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណីដែលពួកគាត់មិនអាចយល់សំណួរដែលគេចោទសួរបាន ។

ដូចគ្នានេះដែរ លោក **ឡុង នរិន្ទ** ដែលបានផ្តល់សក្ខីកម្មពីចម្ងាយតាមរយៈប្រព័ន្ធវីដេអូ ក៏បានទទួលការគាំទ្រគ្រប់គ្រាន់ពីបុគ្គលិកអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញផងដែរ ។ មន្ត្រីអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញម្នាក់

បានជួយជាជំនួយការផ្ទាល់របស់សាក្សីក្នុងពេលកំពុងផ្តល់សក្ខីកម្ម តាំងពីដើមរហូតដល់ចប់ ។ សកម្មភាពនៃការជួយនោះរួមមានដូចជា៖ ការអានសេចក្តីថ្លែងការណ៍របស់សាក្សី ដែលបានផ្តល់ក្នុងពេលសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីជួយរម្លឹកការចងចាំរបស់គាត់មុនពេលផ្តល់ចម្លើយបញ្ជាក់ទៅលើព្រឹត្តិការណ៍ផ្សេងៗ ការធានាថាគាត់បានឮ និងយល់សំណួរដែលចៅក្រម ឬមេធាវីមួយចំនួនធ្វើការចោទសួរពីបន្ទប់សនាការមក ការជួយសួរសំណួរដើមឡើងវិញនៅពេលភាគីពីក្នុងបន្ទប់សនាការចោទសួរ ប្រសិនបើចាំបាច់ ព្រមទាំងការជួយសម្របសម្រួលស្ថានភាពជាក់ស្តែងផ្សេងៗទៀតនៅពេលមានសំណូមពរពីសាក្សី (ឧទាហរណ៍ សាក្សីសុំទៅបន្ទប់ទឹក សុំសម្រាកជាដើម) ។

## *ជំពូកទី៥៖* ការគ្រប់គ្រងសវនាការ

ក្នុងសប្តាហ៍នេះ ទោះបីជាអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយចំនួនទាក់ទងនឹងកង្វល់ផ្នែកដំណើរការនីតិវិធី ក៏ដូចជាបញ្ហានៃការជំទាស់ឡើងផ្សេងៗពីភាគីដែលមិនសូវមានភាពស៊ីចង្វាក់គ្នា និងពិបាកយល់យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបន្តប្រកាន់ខ្ជាប់នូវដំណោះស្រាយយ៉ាងម៉ឺងម៉ាត់ក្នុងការធានាឲ្យបាននូវលំហូរនៃដំណើរការនីតិវិធីមួយដែលមានភាពរលូន និងមានប្រសិទ្ធភាព ។ របៀបចាត់ចែងសំខាន់ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងក្នុងការគ្រប់គ្រងដំណើរការនីតិវិធីនេះ គឺការកំណត់យ៉ាងតឹងរឹងនៅក្នុងការប្រើប្រាស់ពេលវេលារបស់ភាគី សម្រាប់ធ្វើការចោទសួរទៅលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ។ ជាអកុសល មិនទាន់មានភាពច្បាស់លាស់សម្រាប់អ្នកសង្កេតការណ៍ពីខាងក្រៅទៅនៅឡើយទេ ចំពោះភាពសមហេតុផលអ្វីទៅដែលអង្គជំនុំជម្រះកំហិតដល់ការកោះហៅសាក្សីនានាតាមលំដាប់លេខរៀង យ៉ាងណាមិញ រង្វង់ ឬវិសាលភាពមាតិកានៃការផ្តល់សក្ខីកម្ម ក៏នៅតែមានភាពមិនប្រាកដប្រជានៅឡើយ ។ ជាការពិតហើយ គ្រប់គ្នាត្រូវតែទទួលស្គាល់ពីតម្រូវការរបស់អង្គជំនុំជម្រះ ក្នុងការឆ្លើយតបដែលមានលក្ខណៈបត់បែន ទាក់ទងនឹងការបារម្ភផ្នែកសុខភាពរបស់ជនជាប់ចោទ និងសាក្សី ទោះបីជាអាចជះឥទ្ធិពលលើការរៀបចំកាលវិភាគ និងលំហូរនៃការជំនុំជម្រះក៏ដោយ ។ ទាញចេញពីការរ៉ាយរ៉ាប់ខាងលើនេះ វិធីសាស្ត្ររបស់អង្គជំនុំជម្រះក្នុងការគ្រប់គ្រងដំណើរការនីតិវិធីសវនាការរហូតមកទល់ពេលនេះ ហាក់ធ្វើឲ្យមានការច្របូកច្របល់ និងពិបាកយល់បានចំពោះអ្នកចូលរួមជាច្រើនរយនាក់នៅក្នុងសាលសាធារណជន ហើយជាក់ស្តែង យើងក៏បានសង្កេតឃើញថាវាបានផ្តល់នូវភាពតានតឹងចិត្តដល់មេធាវីតំណាងមកពីក្រុមផ្សេងៗក្នុងតុលាការនេះ ក្នុងពេលពួកគេត្រូវជជែកវែកញែកគ្នាលើបញ្ហាណាមួយដែលបានកើតឡើង ។

## ក. ក្តីកង្វល់ពីបញ្ហាសុខភាព ការកំណត់ពេលវេលា និងកាលវិភាគ

ក្តីកង្វល់អំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសុខភាពរបស់សាក្សី បានជះឥទ្ធិពលយ៉ាងខ្លាំងលើការវិវឌ្ឍន៍ក្នុងការជំនុំជម្រះអង្គសេចក្តីទាសប្តាហ៍នេះ និងបានជំរុញឲ្យអង្គជំនុំជម្រះកែប្រែកាលវិភាគជាច្រើនដង ។ ជាឧទាហរណ៍ ដោយគិតអំពីបញ្ហាបច្ចេកទេសដែលអាចកើតឡើងក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់លោក **ឡុង នរិន្ទ** តាមរយៈបណ្តាញវីដេអូ ព្រមទាំងបញ្ហាប្រឈមដែលអាចកើតមានឡើងទាក់ទងនឹងភាពចាស់ជរា (អាយុច្រើន) និងបញ្ហាសុខភាពនោះ លោកប្រធាន **និល ណុន** បានគូសបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូង *"អាចនឹងត្រូវប្រើផែនការ ខ"* ដែលសំដៅលើការគ្រោងផែនការតាមលំដាប់ មានន័យថាបើមានការខកខានក្នុងការអនុវត្តផែនការ *"ក"* ដូច្នេះអង្គជំនុំជម្រះនឹងពិចារណាអនុវត្តផែនការបន្ទាប់ គឺផែនការ *"ខ"*។ ប៉ុន្តែនៅពេលលោក **អៀនូហ្ស៊ី** ស្នើសុំឲ្យអង្គជំនុំជម្រះជួយបញ្ជាក់ឲ្យបានច្បាស់អំពីអ្វីទៅជា *"ផែនការ ខ"* ហើយថាតើផែនការ *"ខ"* នេះមានន័យថា ត្រូវកោះហៅដើមបណ្តឹងរដ្ឋប្បវេណី **រ៉ូម៉ម យ៉ុន** ដើមបណ្តឹងរដ្ឋប្បវេណី លោក **ក្លានហ្វីត** ឬជនជាប់ចោទ **នួន ជា** មកផ្តល់សក្ខីកម្មម្តងទៀត ឬយ៉ាងណា? ចៅក្រម **ខាតវ៉ាយធ៍** បានឆ្លើយតបថាគ្មានទេ *"ផែនការ ខ"* ។ បន្ទាប់មកលោកស្រី **ខាតវ៉ាយធ៍** បានរម្លឹកភាគីទាំងអស់ថា តុលាការត្រូវតែបត់បែនតាមកាលៈទេសៈ ហើយថាមេធាវីក៏ត្រូវចេះបត់បែនតាមកាលៈទេសៈទាំងអស់នេះដែរ។ គេអាចយល់បានជារួមថា ការជំនុំជម្រះនេះកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងប្រហែលជាត្រូវការពេលវេលាមួយចំនួនដើម្បីដើរឲ្យត្រូវតាមយុទ្ធសាស្ត្រគ្រប់គ្រងឲ្យបាននូវការជំនុំជម្រះជាស្តង់ដារមួយ ។

បន្ថែមលើនេះទៀត វាជាការពិតដែលមានកាលៈទេសៈមួយចំនួនតម្រូវឲ្យអង្គជំនុំជម្រះ និងភាគីនៃរឿងក្តីទាំងអស់ត្រូវតែមានភាពបត់បែន បើយើងគិតទៅលើកត្តាផ្សេងៗ ដែលអាចបណ្តាលឲ្យមានការពន្យារពេលក្នុងកិច្ចដំណើរការនីតិវិធី និងការផ្លាស់ប្តូរកាលវិភាគជាដើម។ល។ តែទោះជាយ៉ាងណាក្តី ការគិតគូរពីតម្លាភាព និងការប្រមើលមើលឲ្យបានវែងឆ្ងាយបន្ថែមទៀតពីសំណាក់អង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងឡាយ ពិតជាអាចធ្វើឲ្យការជំនុំជម្រះដំណើរការទៅបានកាន់តែមានប្រសិទ្ធភាព ។

ខណៈពេលដែលអង្គចៅក្រមបានថ្លែងសង្កត់ធ្ងន់ពីតម្រូវការចាំបាច់ដែលបង្ខំឲ្យមានភាពបត់បែន នៅពេលការរៀបចំ និងផ្លាស់ប្តូរកាលវិភាគឡើងវិញដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីដែលមិនទាន់បានស្តាប់ចប់សព្វគ្រប់នៅឡើយ ដោយសារបញ្ហាសុខភាព អង្គចៅក្រមបែរជាបង្ហាញនូវភាពរឹងត្អឹងខ្លាំងតាមរយៈការថ្លែងតបទៅកាន់ភាគីទាក់ទងនឹងការកំណត់ពេលវេលាឲ្យពួកគេធ្វើការចោទសួរទៅលើសាក្សីទៅវិញ ។ ការផ្តល់ពេលសរុប ហាក់ដូចជាត្រូវកំណត់ឡើងតាំងពីដំបូងទីដោយអង្គជំនុំជម្រះ ដោយមិនបានពិចារណាអំពីតម្រូវការ ឬការប្រាថ្នាចង់បានពីភាគីទាំងឡាយក្នុងការអនុវត្តជាក់ស្តែងឡើយ ហើយទោះបីជាមានហេតុផលសមរម្យនៅក្នុងការស្នើសុំពេលវេលាបន្ថែមពីមេធាវីដែលត្រូវធ្វើការចោទសួរ ប្រសិនបើពេលវេលាដែលបានបែងចែកឲ្យគាត់នោះមិនគ្រប់គ្រាន់ ។

ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានបន្តថ្លែងប្រាប់ភាគីទាំងឡាយ ឲ្យយោគយល់នូវស្ថានភាពបន្ទាន់ សូម្បីតែក្នុងករណីខ្លះ អង្គជំនុំជម្រះបានផ្តល់ពេលវេលាបន្ថែមដល់ភាគី ។ នៅពេលមួយនោះ មុនពេលផ្តល់ពេលវេលាបន្ថែម ១៥នាទី ដល់ភាគីសហព្រហ្មរាជអាជ្ញាដើម្បីចោទសួរលោក **រ៉ូម៉ម យ៉ឹន** លោកប្រធានតុលាការគឺ ចៅក្រម **និល ណុន** បានគូសបញ្ជាក់អំពីតម្រូវការឲ្យភាគីទាំងឡាយប្រើពេលវេលាដែលអង្គជំនុំជម្រះបានផ្តល់ជូនឲ្យមានប្រសិទ្ធភាព ។ លោកប្រធានបានថ្លែងយ៉ាងដូច្នេះថា *"ពេលវេលាដើរលឿនណាស់ ហើយមិនដែលរង់ចាំយើងដែរ"* ។ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ពេលបន្ថែមនេះ ដើម្បីអនុញ្ញាតឲ្យភាគីព្រះរាជអាជ្ញា សួរដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទាក់ទងនឹងការជម្លៀសចេញដោយបង្ខំ ប៉ុន្តែតុលាការបានចាត់ទុកការពន្យារពេលសាកសួរនេះ គឺជាការផ្តល់បង្គ្រប់ពេលឲ្យភាគីនេះទៅវិញ ។ អង្គជំនុំជម្រះបានរម្លឹកដល់ភាគីទាំងអស់ឲ្យយកចិត្តទុកដាក់អំពីការកំណត់បែងចែកពេលវេលារបស់ខ្លួនក្នុងពេលអនាគត ។ គេបានរំពឹងទុកថា បញ្ហាប្រឈមក្នុងការរៀបចំដំណើរការនីតិវិធីនេះ នឹងកើតមានឡើងចៀសមិនរួច ជាពិសេសក្នុងការជំនុំជម្រះលើរឿងក្តីដែលមានលក្ខណៈស្មុគស្មាញដូចដែល*អ.វ.ត.ក* កំពុងធ្វើដល់សព្វថ្ងៃនេះ ។ ទោះជាយ៉ាងនេះក្តី វាជាការចាំបាច់ណាស់សម្រាប់អង្គជំនុំជម្រះក្នុងការធានាឲ្យបាននូវការគោរពសិទ្ធិរបស់ភាគីនានា ស្របពេលដែលអង្គជំនុំជម្រះក៏ត្រូវធានាឲ្យបានផងដែរនូវការគ្រប់គ្រងការជំនុំជម្រះមួយឲ្យមានប្រសិទ្ធភាព ។

## ខ. បញ្ហាបកប្រែភាសា

ដើមបណ្តឹងរដ្ឋប្បវេណីពីររូប គឺលោក **ក្លាន ហ្វឿត** និងលោក **រ៉ូម៉ម យ៉ឹន** ដែលបានផ្តល់សក្ខីកម្មក្នុងសប្តាហ៍នេះ មិនមែនជាអ្នកមានដើមកំណើតនិយាយភាសាខ្មែរនោះទេ។ ជាអកុសលណាស់ដែលមិនមានអ្នកបកប្រែអាជីពជាភាសាកាចុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះ ក្នុងពេលពួកគាត់កំពុងផ្តល់សក្ខីកម្ម ដើម្បីធានាឲ្យមានការប្រាស្រ័យទាក់ទងត្រឹមត្រូវមួយ ។ ប៉ុន្តែគួរឲ្យកោតសរសើរដែរ ដែលអង្គជំនុំជម្រះសាលាដំបូងបានធានាឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះទទួលបានជំនួយពីអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញ ដើម្បីសម្រួលដល់ការសួរដេញដោល ។ តុលាការ ធ្វើបានល្អបំផុតក្នុងការដោះស្រាយនូវកាលៈទេសៈនៃដំណើរការនីតិវិធីទាំងស្រុង បើទោះជាមិនទាន់មានភាពល្អឥតខ្ចោះក្តី ជាក់ស្តែងដូចជា ការក្រើនរម្លឹកជារឿយៗដល់ភាគីទាំងអស់ឲ្យរៀបចំសំណួរខ្លីៗ និងឲ្យសាមញ្ញងាយយល់ ។

បញ្ហាមួយផ្សេងទៀតទាក់ទងនឹងការបកប្រែដែលបានកើតឡើងក្នុងសប្តាហ៍នេះ គឺទាក់ទងនឹងល្បឿននៃការចោទសួរដោយសហមេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងដោយព្រះរាជអាជ្ញាជាតិ ។ ពួកគេបាននិយាយលឿនខ្លាំង នៅពេលសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអ្នកបកប្រែមានការលំបាកខ្លាំងក្នុងការបំពេញការងារខ្លួនឲ្យមានប្រសិទ្ធភាព ។ ទោះបីជាយើងមិនអាចបញ្ជាក់បាន ពីចំណុចជាក់លាក់នៃការបាត់បង់ខ្លឹមសារក្នុងការបកប្រែក៏ដោយ ក៏អ្នកបកប្រែបានស្នើសុំជាច្រើនលើកច្រើនសាឲ្យលោកប្រធានតុលាការជួយរម្លឹក

ដល់អ្នកចោទសួរទាំងនេះ សុំឲ្យនិយាយឲ្យបានយឺតៗ ។

### គ. ក្ដីកង្វល់នៃបញ្ហាបច្ចេកទេស

មានការលំបាកបន្តិចបន្តួចទាក់ទងនឹងការតភ្ជាប់វីដេអូពីផ្ទះរបស់សាក្សី **ឡុង នរិន្ទ** នៅក្នុង*ខេត្តបន្ទាយមានជ័យ* ដោយសារតែពេលខ្លះ សម្ភារៈស្ដាប់សម្លេងមិនសូវដំណើរការបានល្អឡើយ ។ កត្តាខាងក្រៅមួយចំនួនក៏បានប៉ះពាល់ដល់បញ្ហាបច្ចេកទេសដែរ ដូចជាការទទួលបានសម្លេងរបស់លោក **ឡុង នរិន្ទ** ឮចូលក្នុងបន្ទប់តុលាការ។ ទីមួយគឺថា មានសម្លេងភ្លេងចេញពីពិធីបុណ្យទានរបស់ផ្ទះអ្នកជិតខាងបានចូលទៅក្នុងឧបករណ៍ស្ដាប់សម្លេងដែលបណ្ដាលឲ្យមានការរំខាន និងតម្រូវឲ្យមានការចោទសួរជាច្រើនដង។ ទីពីរ សក្ខីកម្មរបស់លោក **ឡុង នរិន្ទ** នៅរសៀលថ្ងៃព្រហស្បតិ៍ ត្រូវបានកាត់ផ្ដាច់ដោយសារការដាច់ចរន្តអគ្គីសនីនៅផ្ទះសាក្សី ដែលប្រការនេះបានធ្វើឲ្យដាច់ការតភ្ជាប់វីដេអូផងដែរ ។ ទោះបីជាមានបញ្ហាទាំងនេះក្ដី ជាទូទៅការផ្ដល់សក្ខីកម្មដោយតភ្ជាប់តាមវីដេអូនេះបាន ដំណើរការរហូតដល់ភាគីបានបញ្ចប់សំណួររៀងៗខ្លួន និងបានផ្ដល់នូវជម្រើសដែលអាចដំណើរការទៅបានជំនួសឲ្យការបង្ហាញខ្លួននៅក្នុងបន្ទប់តុលាការសម្រាប់សាក្សីដែលមានវ័យចាស់ជរា និងមានសុខភាពមិនសូវមាំមួន ហើយរស់នៅក្នុងតំបន់ឆ្ងាយពី *អ.វ.ត.ក* ។

### ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | ការសម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ 05/12/11 | 9.02 | 10.29-11.02 | 12.01-13.32 | 14.37–14.59 | 15.21 | 3 ម៉ោង និង 51នាទី |
| ថ្ងៃអង្គារ 06/12/11 | 9.03 | 10.22-11.05 | 12.00-13.35 | 14.45–14.55 | 16.00 | 4 ម៉ោង និង 31នាទី |
| ថ្ងៃពុធ 07/12/11 | 9.15 | 10.20-10.40 | 12.01-13.37 | 14.37–14.57 | 15.59 | 4 ម៉ោង និង 28នាទី |
| ព្រហស្បតិ៍ 06/12/11 | 9.12 | 10.41-11.03 | 12.04-13.34 | 14.46–15.00 | 16.07 | 4 ម៉ោង និង 49នាទី |

**ចំនួនម៉ោងជាមធ្យមក្នុងវគ្គសវនាការនីមួយៗ៖** ៤ ម៉ោង និង ២៤ នាទី

**ចំនួនម៉ោងសរុបក្នុងសប្ដាហ៍នេះ៖** ១៧ ម៉ោង និង ៣៩ នាទី

**ចំនួនម៉ោង ថ្ងៃ សប្ដាហ៍ សរុបក្នុងការជំនុំជម្រះ៖** ២៩ ម៉ោង និង ៥៤ នាទី

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) before the Extraordinary Chambers in the Courts of Cambodia;
- the quotes are based on the personal notes of the trial monitors during the proceedings;
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"* (Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CIA | Central Intelligence Agency |
| CPC | Code of Criminal Procedure of the Kingdom of Cambodia |
| (2007) CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended |
| (2004) ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 |
| (2011) KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the |
| ECCC RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* This issue of KRT Trial Monitor was authored by Mary Kristerie A. Baleva, Samuel Gilg, Princess Principe, Noyel Ry, Kimsan Soy, Penelope Van Tuyl and Flavia Widmer as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, <http://forum.eastwestcenter.org/Khmer-Rouge-Trials/> and <http://socrates.berkeley.edu/~warcrime/>. AIJI is a collaborative project between the East-West Center, in Honolulu, and the University of California, Berkeley War Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia.

1 Trial Chamber. "Severance Order pursuant to Rule 89*ter*." (22 September 2011). E124. [Hereinafter, the **SEVERANCE ORDER**].

2 Trial Chamber. "Notice of Trial Chamber's disposition of remaining pre-trial motions (E20, E132, E134, E135, E124/8, E124/10, E136 and E139) and further guidance to the Civil Party Lawyers". (24 November 2011). E145.

3 OCIJ. "Closing Order". (15 September 2010). D427 [hereinafter, **CLOSING ORDER**] par.1577.391.

4 Rattanakiri Province borders Laos on the North and Vietnam on the East. It was part of the Northeast Zone during the Khmer Rouge regime. This Zone was reportedly run directly by Pol Pot from 1968-1970, and thereafter by Ieng Sary. See Kiernan, Ben. *The Pol Pot Regime: Race Power and Genocide in Cambodia under the Khmer Rouge, 1975-1979, 3rd Edition*. Thailand: Silkworm Books (2002) p. 81.

5 Ieng Sary's revolutionary alias was reportedly "Van". See CLOSING ORDER.

[6] IR 24(1) provides: "Before being interviewed by the Co-Investigating Judges or testifying before the Chambers, witnesses shall take an oath or affirmation in accordance with their religion or beliefs to state the truth." Similarly, Article 328(2) of the CPC states: "before answering the questions, each witness shall swear that he will tell the truth according to his belief or religion."

[7] Trial Chamber. "Provision of Prior Statements to Witnesses in Advance of Testimony at Trial." (24 November 2011). E141/1.1.

[8] SEVERANCE ORDER. See footnote 1.

[9] Ibid. par. 2. 2.

[10] Trial Chamber. "Request for Correction on Document E124/7.1 in English version" (21 November 2011). E124/7.1/Corr-2.

[11] A similar scenario occurred during the preliminary hearing on the fitness to stand trial. See Transcript of Preliminary Hearing on Fitness to Stand Trial, E1/10.1 (31 August 2011), p. 42 f., lines 17-5; 25 -5. See also, AIJI. KRT Trial Monitor Case 002 Issue No. 2 (hearing on fitness to stand trial, 29-31 August 2011). pp. 4-5

[12] ICCPR Article 14; ECCC Law Article 35 new; ICTY Statute Article 21; SCSC Statute Article 17; The Rome Statute Article 63.

[13] In Cambodia, the accused must be present unless he is prevented from being so because of health reasons or other serious reasons. See Constitution of Cambodia Art. 31, Code of Criminal Procedure of the Kingdom of Cambodia Art. 300, 309.

[14] In France, the accused is required to be present before court and if he refuses to appear, he can either be forcibly brought before court or tried in his absence; if he disrupts proceedings he may be expulsed from the courtroom and tried in absentia. However, the accused cannot choose to be tried in his absence unless he is only charged with a misdemeanor. See French Code of Criminal Procedure Art. 319, 320, 322, 411, 413.

[15] In the United States, the accused must be present at the beginning of the trial, but under certain circumstances may not be required to attend the other trial phases or may be able to waive his right to do so. See United States Constitution Amendment 5, 6 and 14; United States Federal Rules of Criminal Procedure Rule 43.

[16] Transcript of Initial Hearing, E1/4.1 (27 June 2011), p. 75, lines 1-20.